# ម៉ូឌុល ១

## តម្រាសម្រាប់អ្នកសម្របសម្រួល

### វគ្គបេសកកម្មពហុគុណ
### ការដាំក្រុមជំនុំដែលមានសុខភាពល្អ

សេចក្តីបញ្ជាក់: តម្រារបស់សិស្ស មានប្រឡោះទំនេរ សម្រាប់គ្រប់ពាក្យដែលគូសបន្ទាត់ពីក្រោម នៅក្នុងតម្រារបស់អ្នកសម្របសម្រួល។ ចម្លើយមាននៅក្នុងប្រអប់ដែលស្ថិតនៅផ្នែកខាងក្រោមនៃទំព័រ។ (កំណត់សម្គាល់នេះ មិនត្រូវបានដាក់បញ្ចូលក្នុងសំណៅជា PDF នៃតម្រានេះទេ)។

revised 3/4/19

# បេសកកម្មពហុគុណ

## ទិដ្ឋភាពទូទៅនៃកម្មវិធីសិក្សាការដាំក្រុមជំនុំ

| | ម៉ូឌុល ១<br>ការដាំក្រុមជំនុំ<br>ដែលមានសុខភាពល្អ | ម៉ូឌុល ២<br>ការត្រៀមរៀបចំដើម្បី<br>ចែកចាយដំណឹងល្អ | ម៉ូឌុល ៣<br>ការយល់ដឹងផែនការ<br>របស់ព្រះ | ម៉ូឌុល ៤<br>ការចែកចាយ<br>ដំណឹងល្អ | ម៉ូឌុល ៥<br>នាំមនុស្សឆ្ពោះ<br>ទៅរកជំនឿ | ម៉ូឌុល ៦<br>ការធ្វើឲ្យសិស្ស<br>រីកចម្រើន |
|---|---|---|---|---|---|---|
| ការចាប់ផ្ដើមជាមួយព្រះ | គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងទេវសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះខាងបេសកកម្មសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | គ្រឹះយុទ្ធសាស្ត្រសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | ការរស់នៅតាមដំណឹងល្អ | ការរីកចម្រើនរបស់គ្រិស្តបរិស័ទ: ព្រះគ្រិស្តជាចំណុចផ្ដោតអារម្មណ៍ (ឬ ព្រះគ្រិស្តជាចំណុចចាប់សព្វ) |
| ម៉ោងទី ១ | **តើក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច?** | **ការធ្វើដែនទីខាងវិញ្ញាណ: គោលការណ៍នៃការស្រាវជ្រាវ** | **អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយការស្រាវជ្រាវរបស់លោកអ្នក** | **ការប្រោសលោះបានសុចរិតដោយសារជំនឿ** | **ឧបសគ្គរារាំងដល់ការផ្សាយដំណឹងល្អ** | **មហាបេសកកម្ម និងការដាំក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | បេសកកម្ម អត្ថបទ និងបរិបទ | និមិត្ត អត្ថបទ និងបរិបទ | ត្រូវបានបញ្ជាក់នៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ២ | **តើអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អមានន័យយ៉ាងដូចម្ដេច?** | **នេះជាអ្វីដែលព្រះយេស៊ូបានធ្វើសម្រាប់ខ្ញុំ! ការអភិវឌ្ឍន៍ និងការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួន** | **អ្វីដែលព្រះកំពុងតែបង្ហាញខ្ញុំ: ការចែកចាយទីបន្ទាល់របស់លោកអ្នក និងការដើរអធិស្ឋាន** | **គោលការណ៍ដឹកនាំនៅក្នុងព្រះគម្ពីរ** | **ដំណើរការនៃការប្រែចិត្ត I** | **គន្លឹះទៅរកភាពជោគជ័យក្នុងការបង្កើតសិស្ស** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ | ការផ្សាយដំណឹងល្អ | និមិត្ត អត្ថបទ និងបរិបទ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៣ | **ការគិត «អ» តើព្រះជាម្ចាស់ចង់បានអ្វី?** | **ការដឹកនាំក្រុមតូច** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការសង្កេតស្គាល់និមិត្តរបស់ព្រះ** | **ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ** | **ដំណើរការនៃការប្រែចិត្ត II** | **ស្គាល់គោលដៅរបស់លោកអ្នក ស្គាល់មនុស្សរបស់លោកអ្នក** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ ការបង្កើតសិស្ស និងការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ | ការបង្កើតសិស្ស |
| ម៉ោងទី ៤ | **វង្វង់នៃការដាំក្រុមជំនុំ** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន II: ការសង្កេតមើលព្រះបន្ទូល** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់បេសកកម្ម** | **ការចាប់ផ្ដើមក្រុមតូច** | **ការផ្សាយដំណឹងល្អក្រុមតូច** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន IV: ការអនុវត្តន៍ព្រះបន្ទូល** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស |
| ម៉ោងទី ៥ | **ហេតុអ្វីក្រុមតូច?** | **របៀបបំផុសការអធិស្ឋានសម្រាប់ក្រុមជំនុំដែលលោកអ្នកបានដាំ** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់គុណតម្លៃ** | **ការផ្សាយដំណឹងល្អ និងការបំពេញសេចក្តីត្រូវការរបស់សហគមន៍** | **ការអនុវត្តន៍៖ បទពិសោធន៍ក្រុមតូច** | **ការយល់ដឹងអំពីគតិលោក** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការបម្រើ | ការផ្សាយដំណឹងល្អ | បញ្ជាក់អះអាងនៅក្នុងការត្រាស់ហៅរបស់ព្រះ |
| ម៉ោងទី ៦ | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន: អនុញ្ញាតឲ្យព្រះគម្ពីរបង្រៀនយើង** | **គោលគំនិតអំពីការអធិស្ឋានទំនុកដម្កើង ៩៥** | **ផែនការមេរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ: ការកំណត់យុទ្ធសាស្ត្រ** | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន III: ការបកស្រាយព្រះបន្ទូល** | **ការធ្វើបទបង្ហាញផែនការមេ** | **គោលគំនិតអំពីការអធិស្ឋានអរព្រះគុណដល់ព្រះសម្រាប់សេចក្តីស្មោះត្រង់របស់ព្រះអង្គ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការថ្វាយបង្គំ | ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស | ការធ្វើសំយោគគំនិត | ការថ្វាយបង្គំ |

| | ម៉ូឌុល ៧<br>ការសង់ក្រុម | ម៉ូឌុល ៨<br>ការសង់ក្រុម | ម៉ូឌុល ៩<br>ការថែទាំមនុស្ស | ម៉ូឌុល ១០<br>ការបង្កើតឲ្យមានក្រុមជំនុំ | ម៉ូឌុល ១១<br>ការរៀបចំផែនការសម្រាប់ពេលអនាគត | ម៉ូឌុល ១២<br>ឆ្ពោះទៅមុខដោយការរួបរួម |
|---|---|---|---|---|---|---|
| ការចាប់ផ្ដើមជាមួយព្រះ | ត្រូវបានបំផ្លាស់បំប្រែដោយសារដំណឹងល្អ | ព្រះគុណមានសម្រាប់អ្នកបន្ទាបខ្លួន | សេចក្ដីស្រឡាញ់ គ្រឹះនៃព័ន្ធកិច្ច | ដើម្បីឲ្យលោកិយបានជឿ យ៉ូហាន ១៧ | ការរាប់តម្លៃ | រហូតដល់លោកិយទាំងមូលញ! |
| ម៉ោងទី ១ | **គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំ** | **ក្រុមការងារ: ការធ្វើការយ៉ាងមានប្រសិទ្ធភាពជាមួយអ្នកដទៃ** | **ការផ្សាយដំណឹងល្អតាមរយៈទំនាក់ទំនង** | **តួនាទីរួមរបស់ក្រុមជំនុំ** | **សេចក្ដីផ្ដើមអំពីភាពជាអ្នកមើលខុសត្រូវ** | **ការដោះស្រាយជម្លោះ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថែទាំសមាជិកក្រុមតូច | ការធ្វើសំយោគគំនិត | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| ម៉ោងទី ២ | **ក្រុមជំនុំ: សរីរាង្គដែលមានជីវិត** | **ការអភិវឌ្ឍន៍ក្រុម** | **ការប្រកបគ្នា** | **ព័ន្ធកិច្ចតាមរយៈអំណោយទានខាងវិញ្ញាណ** | **ភាពជាអ្នកមើលខុសត្រូវផ្នែកហិរញ្ញវត្ថុ** | **ការប្រែចិត្តជាមាគ៌ានៃជីវិត** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការប្រកបគ្នា | ការបំផុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | ភាពជាអ្នកមើលខុសត្រូវលើធនធាន | ការប្រកបគ្នា |
| ម៉ោងទី ៣ | **តើក្រុមមនុស្សក្លាយជាក្រុមជំនុំនៅពេលណា?** | **ភាពរស់រវើកនៃការពិភាក្សានៅក្នុងក្រុមតូច** | **ការថែទាំសហគមន៍របស់យើង** | **របៀបប្រើការស្ទង់រកអំណោយទានខាងវិញ្ញាណ** | ការជួបជុំពិភាក្សាអំពី ការរៀបចំផែនការយុទ្ធសាស្ត្រ I | **ការប្រែចិត្ត និងការស្តារឡើងវិញ: វិន័យក្រុមជំនុំ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការធ្វើសំយោគគំនិត | ការបង្កើតសិស្ស | ការផ្សាយដំណឹងល្អ អត្ថបទ និងបរិបទ | ការបំផុសរូបកាយស្របទៅតាមអំណោយទានខាងវិញ្ញាណ | | ការប្រកបគ្នា |
| ម៉ោងទី ៤ | **វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសនុមាន V: របៀបប្រើការសិក្សាព្រះគម្ពីរបែបវិសេសានុមាន** | **ការហ្វឹកហ្វឺន អ្នកដឹកនាំថ្មីរបស់ក្រុមតូច** | **លក្ខណៈរបស់ក្រុមជំនុំដែលរីកចម្រើន** | **ភាពរស់រវើកនៃសង្គ្រាមខាងវិញ្ញាណ** | | **ការបញ្ជូនអ្នកដទៃឲ្យទៅធ្វើព័ន្ធកិច្ច** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការបង្កើតសិស្ស | ការបង្កើតសិស្ស ការពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការធ្វើសំយោគគំនិត | ការប្រកបគ្នា | | ការពង្រឹងសមត្ថភាពអ្នកដឹកនាំ |
| ម៉ោងទី ៥ | **ប្រវត្តិអ្នកដឹកនាំត្រិស្តបរិស័ទ** | **របៀបទំនាក់ទំនង** | **ការដឹកនាំបែបបម្រើ** | **របៀបដឹកនាំក្រុមជំនុំនៅក្នុងការថ្វាយបង្គំ** | | **ក្រុមជំនុំរបស់យើង និងរូបកាយព្រះគ្រិស្តដែលធំជាង** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ពង្រឹងសមត្ថភាពអ្នកដឹកនាំ | ការថ្វាយបង្គំ | | ការប្រកបគ្នា |
| ម៉ោងទី ៦ | **ការអធិប្បាយតាមព្រះគម្ពីរ I: ការយល់អំពីរាជសារ** | **ការអធិប្បាយតាមព្រះគម្ពីរ II: ការយល់អំពីអ្នកស្តាប់** | **វិធានស្តីអំពីការអធិស្ឋាន: អេភេសូរ ៣–៥** | **ការអធិប្បាយតាមព្រះគម្ពីរ III: ការយល់អំពីខ្លួនឯង** | | **គោលគំនិតអំពីការអធិស្ឋាន: អធិស្ឋានដើម្បីជម្រុញផ្សាយដំណឹងល្អ** |
| គោលគំនិតអំពីក្រុមជំនុំដែលមានសុខភាពល្អ | ការថ្វាយបង្គំ | ការថ្វាយបង្គំ | ការប្រកបគ្នា | ការថ្វាយបង្គំ | ភាពជាអ្នកមើលខុសត្រូវលើធនធាន, ការប្រាប់និមិត្តដ៏ច្បាស់លាស់ | ការផ្សាយដំណឹងល្អ |

បេសកកម្មពហុគុណ
ម៉ូឌុលការដាំក្រុមជំនុំដែលមានសុខភាពល្អ
ព័ន្ធកិច្ចបណ្ដាញពហុគុណ
ក្រុមជំនុំកាន់តែច្រើន / ក្រុមជំនុំកាន់តែរឹងមាំ
**រក្សាសិទ្ធិ © ២០១៥**

មេរៀនហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំនេះ គឺជាការរួមបញ្ចូលគ្នានៃវគ្គសិក្សាអាល់ហ្វ៊ែឌ អូមេហ្គា និងមេរៀនការដាំក្រុមជំនុំដែលមានសុខភាពល្អរបស់ព័ន្ធកិច្ចបណ្ដាញពហុគុណ (MNM)។

MNM បានទទួលការអនុញ្ញាតពីមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ និងពីព័ន្ធកិច្ច Wolrd Ministryដើម្បីបោះពុម្ពមេរៀននេះឲ្យក្រុមជំនុំប្រើ។

លោកអ្នក**ត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឲ្យបោះពុម្ព និងចែកចាយមេរៀននេះ** តាមទម្រង់ណាមួយដែល: (១) ឲ្យតម្លៃប្រភពដើម (២) បញ្ជាក់ប្រាប់ ប្រសិនបើមានការកែសម្រួល (៣) មិនត្រូវយកថ្លៃហួសពីការចំណាយបោះពុម្ព និង (៤) មិនត្រូវថតចម្លង លើសពី ១,០០០ ច្បាប់។

វគ្គអូមេហ្គា:
ការហ្វឹកហ្វឺនអ្នកដាំក្រុមជំនុំ

រក្សាសិទ្ធិ © 2000, 2006 United World Mission.
មេរៀននេះរក្សាសិទ្ធិដើមដោយ The Alliance for Saturation Church Planting ហើយបានរៀបចំឡើងដោយភាពជាដៃគូសហការជាមួយ Peter Deyneka Russian Ministries, Project 250។

ប្រសិនបើលោកអ្នកចង់ដាក់មេរៀននេះនៅលើអ៊ិនធើណេត ឬប្រសិនបើលោកអ្នកមានបំណងចង់ប្រើខុសពីអ្វីដែលបានរៀបរាប់ខាងលើ សូមទំនាក់ទំនង United World Mission, ATTN: Jay Weaver/Omega, 9401-B Southern Pine Blvd., Charlotte, NC 28273-5596, ឬ omega_course@alliancescp.org។

ការបកប្រែ និងការផ្លាស់ប្ដូរស្របតាមបរិបទរបស់លោកអ្នក ក៏ត្រូវបានលើកទឹកចិត្តឲ្យធ្វើផងដែរ។

យើងខ្ញុំសូមអរគុណដល់លោកបណ្ឌិត Jerry Wofford និងលោកបណ្ឌិត Jeff Hale សម្រាប់ការរួមចំណែកដ៏មានតម្លៃរបស់ពួកលោក ក្នុងការរៀបចំមេរៀននេះ។
Gary Teja and John Wagenveld បណ្ណាធិការមេរៀនបេសកកម្មពហុគុណ
**www.multiplicationnetwork.org**

| | គំរូហ្វឹកហ្វឺនសម្រាប់ម៉ូឌុល ១ រយៈពេលមួយថ្ងៃ | |
|---|---|---|
| | សេចក្តីផ្តើមអំពីម៉ូឌុល ១ | 8:00 |
| | ការចាប់ផ្តើមជាមួយព្រះ-<br>គ្រីះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ | 8:15 |
| | ការធ្វើរបាយការណ៍ | 8:30 |
| ម៉ោង<br>ទីមួយ | តើក្រុមជំនុំដែលមានសុខភាពល្អមានន័យដូចម្តេច? | 9:00 |
| | សម្រាក | 10:00 |
| ម៉ោង<br>ទីពីរ | តើអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អមានន័យដូចម្តេច? | 10:15 |
| ម៉ោង<br>ទីបី | ការគិត “អ” (“Z” THINKING:) តើព្រះជាម្ចាស់ចង់បានអ្វី? | 11:15 |
| | អាហារថ្ងៃត្រង់ | 12:15 |
| ម៉ោង<br>ទីបួន | រង្វង់នៃការដាំក្រុមជំនុំ | 1:15 |
| ម៉ោង<br>ទីប្រាំ | ហេតុអ្វីក្រុមតូច? | 2:15 |
| | សម្រាក | 3:15 |
| ម៉ោង<br>ទីប្រាំមួយ | វិធីសាស្រ្តសិក្សាព្រះគម្ពីរបែបវិសេសានុមាន ភាគ ១:<br>អនុញ្ញាតឲ្យព្រះគម្ពីរបង្រៀនយើង | 3:30 |
| | ការបញ្ចប់ | 4:30 |
| | បិទបញ្ចប់ថ្ងៃនោះ | 4:45 |

# ការដាំក្រុមជំនុំដែលមានសុខភាពល្អ
## ម៉ូឌុល ១

កម្មវត្ថុមេរៀនៈ សិក្ខាកាមនឹងអាចប្រាប់បានតាមពាក្យរបស់ខ្លួនៈ
- ក្រុមជំនុំសុខភាពល្អជាអ្វី
- មូលហេតុដែលការដាំក្រុមជំនុំសុខភាពល្អមានសារៈសំខាន់ និង
- ដំណើរការគ្រឹះនៅក្នុងការដាំក្រុមជំនុំដែលមានសុខភាពល្អ

សេចក្តីផ្តើមអំពីម៉ូឌុល ១

ពាក្យពេចន៍ណែនាំរបស់អ្នកសម្របសម្រួល (២ នាទី)
- ស្វាគមន៍សិក្ខាកាមដោយភាពកក់ក្តៅ រាក់ទាក់ និងភាពសាទរ។
- នាំមុខសិក្ខាកាមដោយអធិស្ឋានខ្លីជាមួយគ្នា ថ្វាយថ្ងៃនោះសម្រាប់ជាសិរីល្អដល់ព្រះ។

សកម្មភាពធ្វើឲ្យស្គាល់គ្នា (៥ នាទី): បីពាក្យ
ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ
- ប្រាប់សិក្ខាកាមឲ្យគិតរកបីពាក្យ ដែលពណ៌នាប្រាប់អំពីខ្លួនគេ។
- ប្រាប់សិក្ខាកាមថាមានមនុស្សប៉ុន្មាននាក់នៅក្នុងក្រុម និងមានរយៈពេល ៤ នាទី ដើម្បីជម្រាបសួរមនុស្សគ្រប់គ្នានៅក្នុងថ្នាក់ ណែនាំខ្លួន និងចែកចាយប្រាប់បីពាក្យរបស់គេ។
- ចុងបញ្ចប់ មើលថាតើមានមនុស្សប៉ុន្មាននាក់បានជួបមនុស្សគ្រប់គ្នានៅក្នុងថ្នាក់។ លោកអ្នកប្រហែលជាចង់សួរចំនួនមនុស្សដែលពួកគេបានទំនាក់ទំនងជាមួយ។ ឧទាហរណ៍ ប្រសិនបើមានសិក្ខាកាម ២០ នាក់ៈ តើមានប៉ុន្មាននាក់បាននិយាយជាមួយមនុស្ស ១០ នាក់ ឬលើសពី១០, ១៥នាក់, ២០ នាក់?ចូរអបអរ និងសប្បាយរីករាយជាមួយគ្នា។

ឧទាហរណ៍ៈ
សួស្តី ខ្ញុំឈ្មោះ ម៉ារី
ខ្ញុំចង់ប្រាប់ថា ខ្ញុំជាមនុស្សដែលចង់ចេះចង់ដឹង មានចិត្តល្អ និងឧស្សាហ៍។

សកម្មភាពក្រុមជំនុំដែលមានសុខភាពល្អ និងមិនមានសុខភាពល្អ (៨ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: សកម្មភាពនេះមានគោលបំណងជួយសិក្ខាកាមឲ្យផ្តោតអារម្មណ៍ភ្លាមៗទៅលើចំណេះដឹង ជំនាញ និងឥរិយាបថដែលតម្រូវឲ្យមាន សម្រាប់ការដាំក្រុមជំនុំដែលមានសុខភាពល្អ។

- ចូរនិយាយថា: «លោកអ្នកម្នាក់ៗសុទ្ធតែនាំយកបទពិសោធន៍ដ៏មានតម្លៃពីក្រុមជំនុំមកក្នុងវគ្គហ្វឹកហ្វឺន អំពីអ្នកដាំក្រុមជំនុំនេះ។ ម៉ូឌុលនេះមានគោលបំណងជួយលោកអ្នកពណ៌នាអំពីលក្ខណៈរបស់ក្រុមជំនុំដែលមានសុខភាពល្អ និងអ្វីដែលត្រូវការ ដើម្បីដាំក្រុមជំនុំដែលមានសុខភាពល្អ»។
- ចូរចែកថ្នាក់ទៅជាពីរក្រុមតូចៗ។ នៅក្នុងរយៈពេល ៤ នាទី សូមឲ្យក្រុម «ក» កត់ត្រាលក្ខណៈរបស់ក្រុមជំនុំដែលមានសុខភាពល្អ ឲ្យបានច្រើនតាមដែលអាចធ្វើបាន តាមដែលពួកគេអាចគិតឃើញ ដោយផ្អែកលើបទពិសោធន៍របស់ពួកគេ។ ដូចគ្នាដែរ សូមឲ្យក្រុម «ខ» កត់ត្រាលក្ខណៈរបស់ក្រុមជំនុំដែលមិនមានសុខភាពល្អ ឲ្យបានច្រើនតាមដែលអាចធ្វើបាន តាមដែលពួកគេអាចគិតឃើញ ដោយផ្អែកលើបទពិសោធន៍របស់ពួកគេ។
- ចូរអនុញ្ញាតឲ្យក្រុមនីមួយៗមានពេល ១ នាទី ដើម្បីរាយការណ៍ប្រាប់បញ្ជីលក្ខណៈរបស់គេ។
- ចូរនិយាយថា: «ថ្ងៃនេះ យើងនឹងរៀនលក្ខណៈ ១០ យ៉ាង ដែលបណ្តាញពហុគុណរកឃើញថាជាលក្ខណៈសំខាន់របស់ក្រុមជំនុំដែលមានសុខភាពល្អ។ ទោះបីយ៉ាងណាក៏ដោយ ជាដំបូងនេះ យើងនឹងពិចារណាជាមួយគ្នាអំពីហេតុផលចំនួនប្រាំនៅក្នុងព្រះគម្ពីរ សម្រាប់ការដាំក្រុមជំនុំដែលមានសុខភាពល្អ»។

## ការចាប់ផ្តើមជាមួយព្រះ
គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមជំនុំដែលមានសុខភាពល្អ (១៥ នាទី)

សកម្មភាពបើក **(២ នាទី)**
ការណែនាំសម្រាប់អ្នកសម្របសម្រួល: សូមឲ្យសិក្ខាកាមចែកចាយគំនិតរបស់ពួកគេអំពីមូលហេតុសម្រាប់ដាំក្រុមជំនុំដែលមានសុខភាពល្អ។ សូមឲ្យសិក្ខាកាមស្តាប់ ដើម្បីមើលថាតើលក្ខណៈណាខ្លះក្នុងចំណោមលក្ខណៈទាំងនេះ ដែលត្រូវបានលើកឡើងនៅក្នុងមេរៀននេះ។

ចូរបែងចែកខគម្ពីរសម្រាប់ហេតុផលនីមួយៗនៅក្នុងព្រះគម្ពីរ ឲ្យទៅសិក្ខាកាមផ្សេងៗគ្នា។ ចូរដឹកនាំក្រុមរកឲ្យឃើញហេតុផលនីមួយៗនៅក្នុងព្រះគម្ពីរ ចេញពីខគម្ពីរដែលបានអាន ហើយបំពេញនៅក្នុងប្រឡោះដែលត្រឹមត្រូវ នៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ការចាប់ផ្តើមដោយសិក្សាព្រះគម្ពីរ (១៣ នាទី)
មានហេតុផលប្រាំនៅក្នុងព្រះគម្ពីរសម្រាប់ការដាំក្រុមជំនុំថ្មីដែលមានសុខភាពល្អ:

១. ដោយព្រោះព្រះជាម្ចាស់ជាឪពុកដែលស្វែងរក ហើយរកឃើញកូនដែលបាត់បង់។
ខគម្ពីរគន្លឹះ | លោកុប្បត្តិ ៣:៩, ទំនុកតម្កើង ២៣, លូកា ១៥:១៥-២៤

២. ដោយព្រោះសេចក្តីស្រឡាញ់របស់ព្រះគ្រិស្តបង្ខំយើង។
ខគម្ពីរគន្លឹះ | ២ កូរិនថូស ៥:១៤-២០, ម៉ាថាយ ១៨:១២-១៤, យ៉ូហាន ១៤:២៣

៣. ដោយព្រោះព្រះវិញ្ញាណបរិសុទ្ធ ត្រូវបានចាត់មកឯមនុស្សទាំងអស់។
ខគម្ពីរគន្លឹះ | កិច្ចការ ២:៥-១១, ១០:៤៤-៤៨, ១:៨

៤. ដោយព្រោះក្រុមជំនុំមូលដ្ឋាន ជាមែកនៃព្រះរាជ្យរបស់ព្រះ។
ខគម្ពីរគន្លឹះ | ១ ពេត្រុស ២:៥, ៩-១០, ១២; កូឡុស ១:១៣-២៣, រ៉ូម ១២:៤-៨

៥. ពីព្រោះការដាំក្រុមជំនុំថ្មីថ្វាយសិរីល្អដល់ព្រះជាម្ចាស់។
ខគម្ពីរគន្លឹះ | អេភេសូរ ១:១-១៤, វិវរណៈ ៧:៩-១២

ឪពុក - ស្វែងរក - រកឃើញ - សេចក្តីស្រឡាញ់- របស់ព្រះគ្រិស្ត - ព្រះវិញ្ញាណបរិសុទ្ធ - មែក - ព្រះរាជ្យ - សិរីល្អ - ព្រះជាម្ចាស់

ការរាយការណ៍

ការណែនាំដោយសង្ខេបរបស់អ្នកសម្របសម្រួល: ដោយព្រោះមិនតម្រូវឲ្យមានការរាយការណ៍នៅក្នុងម៉ូឌុលនេះ ចូរប្រើពេលនេះដើម្បី ១) សង្ខេបវគ្គសិក្សាទាំងមូល និង ២) ពន្យល់ប្រាប់អំពីលក្ខខណ្ឌនៅក្នុងការរាយការណ៍ និងទម្រង់ដែលនឹងត្រូវប្រើសម្រាប់គ្រប់ម៉ូឌុលទាំងអស់។

ទិដ្ឋភាពទូទៅនៃការដាំក្រុមជំនុំដែលមានសុខភាពល្អ ដោយប្រើវគ្គសិក្សាបេសកកម្មពហុគុណ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរសូមឲ្យសិក្ខាកាមកត់ត្រាជំហានទាំងប្រាំសម្រាប់ការដាំក្រុមជំនុំនៅក្នុងក្រាហ្វិច ដែលមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ។ ចូរចាប់ផ្ដើមជាមួយនឹងជំហានដំបូង ដែលជាការផ្សាយដំណឹងល្អ រួចបន្តរហូតដល់ជំហានចុងក្រោយ ដែលជាការថ្វាយបង្គំ និងការបម្រើ។

## ជំហានប្រាំដើម្បីដាំក្រុមជំនុំ




ការថ្វាយបង្គំ & ការបម្រើ – ការដឹកនាំ – ការប្រកបគ្នា – ការបង្កើតសិស្ស – ការផ្សាយដំណឹងល្អ

ទិដ្ឋភាពទូទៅនៃការរាយការណ៍អំពីការដាំក្រុមជំនុំដែលមានសុខភាពល្អ (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- នាំសិក្ខាកាមបើកទៅរកទិដ្ឋភាពទូទៅអំពីវគ្គសិក្សា នៅខាងដើមសៀវភៅលំហាត់។
- ពន្យល់ប្រាប់អំពីរចនាសម្ព័ន្ធរបស់វគ្គសិក្សា (១២ ម៉ូឌុល ដែលនៅក្នុងម៉ូឌុលនីមួយៗមានប្រាំមួយម៉ោងសិក្សា)។
- សូមឲ្យសិក្ខាកាមនីមួយៗអានចំណងជើងរបស់ម៉ោងសិក្សាទាំង ៦ នៅក្នុងម៉ូឌុល ១។ ចូរសួរពួកគេអំពីរបៀបដែលពួកគេផ្សាភ្ជាប់ម៉ោងសិក្សានីមួយៗ ទៅនឹងជំហានប្រាំដើម្បីដាំក្រុមជំនុំ។
- ចូររំឭកឡើងវិញកាលបរិច្ឆេទ និងរឿងភស្តុភារដទៃទៀតដែលពាក់ព័ន្ធនឹងការបញ្ចប់ម៉ូឌុលទាំង ១២។
- ចូរចំណាយពេលឆ្លើយសំណួររបស់សិក្ខាកាម អំពីការរចនា និងខ្លឹមសាររបស់វគ្គសិក្សាព្រមទាំងរឿងភស្តុភារ។
- សុំឲ្យសិក្ខាកាមបើកទៅទំព័រនៅក្នុងសៀវភៅលំហាត់របស់ពួកគេ ដែលមាន “កខគ” របស់អ្នកដាំក្រុមជំនុំ: របាយការណ៍ប្រចាំខែ។ ចូរពន្យល់ប្រាប់អំពីលក្ខខណ្ឌនៅក្នុងការធ្វើរបាយការណ៍សម្រាប់វគ្គសិក្សានេះ។
- ចូរពន្យល់អំពីរបៀបបំពេញទម្រង់នោះ។
- ចូរពន្យល់អំពីរបៀបដែលក្រុមត្រូវរាយការណ៍ប្រាប់គ្នាទៅវិញទៅមក នៅក្នុងអំឡុងពេលម៉ោងសិក្សា អំពីការរាយការណ៍ដែលមាននៅក្នុងម៉ូឌុល ២ ដល់ ១២។

# របាយការណ៍ដាំក្រុមជំនុំកខគ

របាយការណ៍ប្រចាំខែ

## ព័ត៌មានទូទៅ

| | | | | |
|---|---|---|---|---|
| របាយការណ៍ខែ | | បានជួបប្រជុំជាមួយគ្រូឧបជ្ឈា | បាទ/ចាស | ទេ |

| | |
|---|---|
| ឈ្មោះអ្នកដាំក្រុមជំនុំ | |
| តំបន់របស់អ្នកដាំក្រុមជំនុំ | |
| អ្នកសម្របសម្រួលតំបន់ | |

## បុគ្គល

| | |
|---|---|
| អ្នកថ្មីដែលត្រូវទាក់ទង<br>អ្នកដែលត្រូវបានទាក់ទងនៅក្នុងបរិបទដាំក្រុមជំនុំ ដើម្បីប្រាប់ដំណឹងល្អ | |
| ការប្រែចិត្តថ្មី<br>អ្នកដើរតាមព្រះយេស៊ូ | |
| អ្នកថ្មីដែលបានទទួលបុណ្យជ្រមុជទឹក<br>អ្នកដែលបានទទួលពិធីបុណ្យជ្រមុជទឹក | |
| អ្នកដឹកនាំថ្មីដែលកំពុងទទួលការហ្វឹកហ្វឺន<br>អ្នកដែលអ្នកដាំក្រុមជំនុំកំពុងហ្វឹកហ្វឺនឲ្យធ្វើជាអ្នកដឹកនាំ | |

## ក្រុមតូចៈ ជាអប្បបរិមា សិស្សថ្មីពីរនាក់ និងអ្នកដឹកនាំម្នាក់

| | |
|---|---|
| ក្រុមតូចថ្មី<br>ក្រុមដែលបានចាប់ផ្តើមខែនេះ | |
| អ្នកចូលរួមថ្មីនៅក្នុងក្រុមតូច<br>មនុស្សថ្មីដែលចូលរួមក្រុមតូចនៅខែនេះ | |
| អ្នកដឹកនាំថ្មីដែលមានមួយក្រុម<br>អ្នកដឹកនាំថ្មីដែលមានមួយក្រុមនៅក្រោមការត្រួតពិនិត្យមើលរបស់អ្នកដាំពួកជំនុំ | |

## សំណូមពរអធិស្ឋាន

១. ______________________________

______________________________

២. ______________________________

______________________________

៣. ______________________________

______________________________

## ទីបន្ទាល់

______________________________

______________________________

______________________________

## ម៉ោងទី ១

តើក្រុមជំនុំដែលមានសុខភាពល្អមានន័យដូចម្ដេច? (៦០ នាទី)

## ករណីសិក្សា: រឿងអំពីក្រុមជំនុំមួយដែលមិនមានសុខភាពល្អ (១០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ករណីសិក្សានាំសិក្ខាកាមឲ្យមានបទពិសោធន៍ជាមួយស្ថានភាពបញ្ហាពិតប្រាកដនៅក្នុងជីវិត ដើម្បីឲ្យសិក្ខាកាមទទួលបានការយល់ដឹងអំពីលក្ខណៈទាំងដប់របស់ក្រុមជំនុំដែលមានសុខភាពល្អ។ ករណីសិក្សាចាប់ផ្ដើមឡើងដោយពណ៌នាអំពីក្រុមជំនុំដែលមិនមានសុខភាពល្អ ជាពិសេសក្រុមជំនុំដែលត្រូវបានដាំ តាមរបៀបដែលមិនមានសុខភាពល្អ។

- សុំសិក្ខាកាមឲ្យអាន«រឿងអំពីក្រុមជំនុំដែលមិនមានសុខភាពល្អ»។
- សុំសិក្ខាកាមឲ្យពណ៌នាអំពីកត្តាចង្អុលបង្ហាញជាក់លាក់មួយចំនួនដែលប្រាប់អំពីស្ថានភាពមិនមានសុខភាពល្អរបស់ក្រុមជំនុំ។
- ចូរពិភាក្សាជាមួយសិក្ខាកាមអំពីរបៀបដែលកត្តាចង្អុលបង្ហាញទាំងនេះពាក់ព័ន្ធជាមួយនឹងជំហានទាំងប្រាំសម្រាប់ការដាំក្រុមជំនុំ។
- ចូរសួរថា: «តើក្រុមជំនុំនេះចាប់ផ្ដើមត្រឡប់ជាក្រុមជំនុំដែលមិនមានសុខភាពល្អនៅពេលណា?» សិក្ខាកាមគួរតែទទួលស្គាល់ថា ក្រុមជំនុំនេះស្ថិតនៅលើគន្លងមួយដែលមិនមានសុខភាពល្អ ចាប់តាំងពីក្រុមជំនុំនេះត្រូវបានដាំពីដំបូង។
- ចូរនិយាយថា: «ម៉ោងនេះមានគោលបំណងឲ្យលោកអ្នកទទួលបានការយល់ដឹងអំពីសារៈសំខាន់នៃលក្ខណៈទាំងដប់របស់ក្រុមជំនុំដែលមានសុខភាពល្អ ដើម្បីឲ្យលោកអ្នកសង់លក្ខណៈទាំងនោះទៅក្នុងក្រុមជំនុំរបស់លោកអ្នក នៅពេលដែលលោកអ្នកដាំ។ មិនដូចជាក្រុមជំនុំហូសាណាឡើយ ក្រុមជំនុំថ្មីរបស់លោកអ្នកនឹងចាប់ផ្ដើមឡើងមានសុខភាពល្អតាំងពីដំបូង!»។

### *រឿងអំពីក្រុមជំនុំដែលមិនមានសុខភាពល្អ*

នៅពេលដែលក្រុមជំនុំហូសាណាត្រូវបានដាំកាលពីដំបូង ក្រុមជំនុំនេះបានចាប់ផ្ដើមឡើងជាមួយនឹងជម្លោះ និងការឈឺចាប់។ យោងទៅតាមប្រវត្តិក្រុមជំនុំ ការសម្រេចចិត្តដាំក្រុមជំនុំហូសាណា កើតចេញពីជម្លោះរវាងភាគីមួយនៅក្នុងក្រុមជំនុំដែលគោរពគ្រូគង្វាលរៀមច្បងដែលបានចូលនិវត្ត និងភាគីមួយទៀតដែលស្មោះស្ម័គ្រនឹងគ្រូគង្វាលរៀមច្បងនៅពេលបច្ចុប្បន្ន។ នៅទីបំផុត និកាយបានសម្រេចចិត្តបំបែកក្រុមជំនុំទៅជាពីរ ហើយក្រោយមក ក្រុមជំនុំថ្មីមួយក្នុងចំណោមក្រុមជំនុំថ្មីទាំងពីរនោះ បានដាក់ឈ្មោះក្រុមជំនុំថា ហូសាណា។ លោកគ្រូ លី ត្រូវបានជ្រើសរើសឲ្យធ្វើជាគ្រូគង្វាលរៀមច្បងដំបូងរបស់ក្រុមជំនុំថ្មីនោះ។ មិនយូរប៉ុន្មាន គាត់មានជម្លោះជាមួយពួកចាស់ទុំ ពួកគាត់ក៏ចេញពីក្រុមជំនុំ ទាំងមានសមាជិកខ្លះទៅជាមួយ។

នៅក្នុងក្រុមជំនុំនេះ ចាស់ទុំទាំងប៉ុន្មានសុទ្ធតែមានអាយុជាង ៥៥ ឆ្នាំ។ ទាំងមនុស្សធំ ទាំងយុវវ័យ សុទ្ធតែមិនទុកចិត្តអ្នកដឹកនាំក្រុមជំនុំ។ ការមិនទុកចិត្តនេះ គឺជាហេតុផលមួយដែលក្រុមជំនុំហូសាណាបានបែកចេញពីក្រុមជំនុំដើម។ ក្រុមជំនុំហូសាណាមិនងាយទទួលយកការផ្លាស់ប្ដូរ តាមទិសដៅដែលធ្វើឲ្យមានសុខភាពរឹងមាំឡើងវិញទេ។ ដោយសារសមាជិកក្រុមជំនុំមានវ័យខុសគ្នា ក្រុមជំនុំហូសាណារឹតតែពិបាកធ្វើការផ្លាស់ប្ដូរដែលចាំបាច់ ដើម្បីក្លាយជាក្រុមជំនុំមួយដែលរឹងមាំ។

របៀបថ្វាយបង្គំតាមបែបបុរាណ ជាបញ្ហាមួយធំ ពីព្រោះមានតែសមាជិកក្រុមជំនុំចាស់ៗប៉ុណ្ណោះដែលចូលចិត្ត។ អាគារអាចដាក់អ្នកចូលរួមបានប្រហែល ១០០០ នាក់ ប៉ុន្ដែអ្នកចូលរួមថ្វាយបង្គំនៅថ្ងៃអាទិត្យ ជាមធ្យម មាន ២០០ នាក់។ បញ្ហាទាំងនេះ គ្រាន់តែជាបំណែកតូចៗដែលគេមើលឃើញ។

ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមជំនុំមានភាពយ៉ាប់យ៉ឺន។ នៅរដូវត្រជាក់ ពួកគេមិនប្រើម៉ាស៊ីនកំដៅទេ ដោយព្រោះស្ថានភាពហិរញ្ញវត្ថុមិនល្អរបស់ក្រុមជំនុំ។ នៅរដូវក្តៅ ក៏មានបញ្ហាដូចគ្នានេះដែរ ពាក់ព័ន្ធនឹងម៉ាស៊ីនត្រជាក់។ ក្រុមជំនុំជំពាក់បំណុល។ អ្វីដែលអាក្រក់ជាងនេះទៅទៀត អ្នកដឹកនាំក្រុមជំនុំមិនបានប្តូរផ្តាច់ក្នុងការថ្វាយតង្វាយមួយភាគដប់។ ប្រព័ន្ធថែបំប៉នអ្នកជឿថ្មី ក៏លែងមាន។ ក្រុមតូច គ្រាន់តែជាក្រុមថ្លូវការសម្រាប់ស្ត្រី ដូចគ្នាជាមួយនឹងក្រុមតូចដទៃៗទៀតសម្រាប់សមាជិកក្រុមជំនុំ។ ក្រុមទាំងនេះមិនបានបង្កើតផលបន្តតាមរយៈការផ្សាយដំណឹងល្អទេ។ បញ្ហាចេះតែបន្ត ការបែកបាក់ ហើយភាពមិនស្មោះត្រង់ចំពោះគ្នាតែងតែមាននៅក្នុងក្រុមជំនុំហូសាណា។ ទាំងអស់នេះជាការសង្ខេបស្ថានភាពដ៏គួរឲ្យសោកសង្រេងរបស់ក្រុមជំនុំហូសាណា មុនពេលដែលក្រុមជំនុំឆ្លងកាត់ដំណើរការផ្លាស់ប្តូរ ដើម្បីមានសុខភាពល្អឡើងវិញ។

ដកស្រង់ចេញពីៈ Park, H. W. (2009)។ យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពសម្រាប់ធ្វើឲ្យក្រុមជំនុំមានសុខភាពល្អឡើងវិញ តាមរយៈករណីសិក្សាអំពីក្រុមជំនុំហូសាណា (និក្ខេបបទថ្នាក់បណ្ឌិតនៅសាលាព្រះគម្ពីរ Liberty Baptist Theological Seminary)[១]។

[១] ដកស្រង់ចេញពី *http://digitalcommons.liberty.edu/cgi/viewcontentcgi?article=1170& context=doctoral*

លក្ខណៈ ១០ យ៉ាងរបស់ក្រុមជំនុំដែលមានសុខភាពល្អ (៤០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ដឹកនាំសិក្ខាកាមឲ្យបំពេញក្រាហ្វិចខាងក្រោម នៅពេលដែលលោកអ្នកពិភាក្សាអំពីប្រធានបទ នីមួយៗ។
- ក៏សុំសិក្ខាកាមឲ្យកត់ត្រានៅក្នុងសៀវភៅលំហាត់របស់ពួកគេផងដែរ។




ចូរនិយាយថា: «លក្ខណៈទាំង១០ មានកត្តាប្រាំ និងតួនាទីប្រាំ»។ ចូរសុំឲ្យសិក្ខាកាមបំពេញកត្តាប្រាំ និងតួនាទីប្រាំ នៅត្រង់កន្លែងដែលបានផ្តល់ឲ្យនៅក្នុងក្រាហ្វិច។

ចូរនិយាយថា: «ចូរចាប់ផ្តើមជាមួយនឹងកត្តាទាំងប្រាំ»។ ចូរសុំឲ្យសិក្ខាកាមបំពេញនៅក្នុងក្រាហ្វិច និងកត់ត្រានៅក្នុងប្រឡោះដែលបានផ្តល់ឲ្យ នៅពេលដែលលោកអ្នកចែកចាយព័ត៌មាននេះតាមរបៀបបង្រៀន។

កត្តាប្រាំរបស់ក្រុមជំនុំដែលមានសុខភាពល្អ (២០ នាទី)

១. និមិត្តច្បាស់លាស់
និយមន័យ: ការមាននិមិត្តមានន័យថា មើលឆ្ពោះទៅពេលអនាគតឃើញអ្វីដែលព្រះជាម្ចាស់ចង់ធ្វើ តាមរយៈលោកអ្នក ដើម្បីសម្រេចគោលបំណងប្រោសលោះរបស់ព្រះអង្គ។

»ក្រុមជំនុំមើលឃើញច្បាស់ពីអ្វីដែលព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំក្លាយជាអ្វី ហើយធ្វើអ្វី ដើម្បីឲ្យរូបភាពរបស់ព្រះគ្រិស្ទ និងរៀបរាប់អំពីការកើតជាថ្មី នៅក្នុងសហគមន៍«។
កត្តាប្រាំ - និមិត្ត - ការដឹកនាំ - រូបកាយដែលត្រូវបានបំផុស - ជនធាន - អត្ថបទ និងបរិបទ - ក្រុមជំនុំ - តួនាទីប្រាំ- ការផ្សាយដំណឹងល្អ - ការបង្កើតសិស្ស - ការបម្រើ - ការប្រកបគ្នា – ការថ្វាយបង្គំ –និមិត្ត – ព្រះជាម្ចាស់ – តាមរយៈ – គោលបំណងប្រោសលោះ – ព្រះជាម្ចាស់

តើព្រះជាម្ចាស់ចង់ឲ្យក្រុមជំនុំដែលលោកអ្នកកំពុងដាំក្លាយជាអ្វី និងធ្វើអ្វី? នៅក្នុងអំឡុងពេលហ្វឹកហ្វឺន លោកអ្នកនឹងសរសេរសេចក្តីប្រកាសនិមិត្ត ដែលសង្ខេបអ្វីដែលព្រះជាម្ចាស់កំពុងត្រាស់ហៅលោកអ្នកឲ្យក្លាយជាអ្វី ហើយធ្វើអ្វី ក្នុងនាមជាក្រុមជំនុំ។ ចូរប្រើសេចក្តីប្រកាសនេះ ដើម្បីនៅតែផ្តោតជាប់ក្នុងព័ន្ធកិច្ចលោកអ្នក។

២. ការផ្តល់សិទ្ធិអំណាចអ្នកដឹកនាំ
និយមន័យ: ការដឹកនាំបែបគ្រិស្តបរិស័ទ អាចត្រូវបានឲ្យនិយមន័យដូចតទៅ: «អ្នកដឹកនាំគ្រិស្តបរិស័ទ គឺជាមនុស្សដែលប្តូរផ្តាច់ចំពោះព្រះ (ចរិត) ជាអ្នកដែលស្គាល់កន្លែងដែលខ្លួនកំពុងទៅ

(និមិត្ត) និងមានអ្នកដើរតាម (ឥទ្ធិពល)»។

«ក្រុមជំនុំទទួលបានការបម្រើពីអ្នកដែលយល់អំពីនិមិត្តក្រុមជំនុំ អាចចែកចាយនិមិត្តនោះយ៉ាងច្បាស់លាស់ប្រាប់ក្រុមជំនុំ និងអាចរៀបចំរចនាសម្ព័ន្ធរូបកាយរបស់ព្រះគ្រិស្ត ដើម្បីឲ្យនិមិត្តនោះក្លាយទៅជាការពិត»។

ចូរនិយាយថា: »ចូរមើលដោយសង្ខេបរបៀបដែលលោកប៉ុលបានអភិវឌ្ឍ និងផ្តល់អំណាចអ្នកដឹកនាំ»។

- សូមឲ្យអ្នកណាម្នាក់អាន ២ ធីម៉ូថេ ២:២

ចូរនិយាយថា: »សម្រាប់លោកប៉ុល ការផ្តល់អំណាចអ្នកដឹកនាំក្រុមជំនុំមូលដ្ឋាននីមួយៗ មានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឲ្យក្រុមជំនុំនៅស្ថិតស្ថេរ។ នេះជាអ្វីដែលលោកបានធ្វើ:

ក. លោកបានផ្តល់ឱកាសឲ្យអ្នកដឹកនាំ។ លោកបានដាក់ឲ្យពួកគេមានការទទួលខុសត្រូវលើ
ការងារ។
ខ. លោកប្តូរផ្តាច់ក្នុងការរៀបចំពួកគេ។
គ. លោកទុកចិត្តពួកគេ។

៣. រូបកាយដែលបានបំផុស
និយមន័យ: «សមាជិកក្រុមជំនុំធ្វើការជាមួយគ្នា ដោយប្រើអំណោយទានរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍»។

»គឺដោយខំបម្រើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបានទទួលមក ទុកដូចជាអ្នកចែកចាយយ៉ាងល្អនៃព្រះគុណដ៏បែកជាច្រើនផ្លូវវិញ បើអ្នកណាអធិប្បាយ នោះត្រូវតែអធិប្បាយ ដូចជាអ្នកដែលបញ្ចេញព្រះបន្ទូលនៃព្រះ ហើយបើអ្នកណាបម្រើ នោះត្រូវបម្រើដោយកម្លាំងដែលព្រះប្រទានឲ្យ ដើម្បីឲ្យព្រះបានថ្កើងឡើងក្នុងគ្រប់ការទាំងអស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់មានសិរីល្អ និងព្រះចេស្តានៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន» **(១ ពេត្រុស ៤:១០-១១)។**

*ជំហានអនុវត្តប្រាំនៅក្នុងការបំផុសសមាជិក*

I. រៀបចំការដឹកនាំរបស់លោកអ្នកឲ្យបំផុសក្រុមជំនុំទាំងមូល
II. បង្រៀនអំពីអំណោយទានខាងវិញ្ញាណ និងភាពជាអ្នកមើលខុសត្រូវលើទេពកោសល្យ
III. សម្គាល់អំណោយទាន និងចំណង់ចំណូលចិត្តរបស់អ្នកជឿម្នាក់ៗនៅក្នុងក្រុមជំនុំ
IV. សុំឲ្យសមាជិកម្នាក់ៗធ្វើការនៅក្នុងពន្ធកិច្ច ឬផ្នែកណាមួយនៃការបម្រើ
V. សង្កេតមើលរបៀបដែលផ្នែកនានានៃជីវិតក្រុមជំនុំកំពុងដំណើរការ ហើយធ្វើការកែសម្រួលដែលចាំបាច់

៤. ការមើលខុសត្រូវលើធនធាន
និយមន័យ: ក្រុមជំនុំជំរុញសមាជិករបស់ខ្លួនឲ្យធ្វើជាអ្នកមើលខុសត្រូវល្អលើទ្រព្យសម្បត្តិធនធាន និងអ្វីៗដែលជារបស់ពួកគេ។ ការមើលខុសត្រូវ គឺជាការប្រើអំណោយទានខាងសាច់ឈាម និងខាងហិរញ្ញវត្ថុទាំងនេះ ដើម្បីសម្រេចកិច្ចការរបស់ព្រះរាជ្យនៅក្នុងក្រុមជំនុំ និងនៅក្នុងសហគមន៍របស់ខ្លួន។

»ចូរថ្វាយកិត្តិនាមដល់ព្រះយេហូវ៉ា ដោយទ្រព្យសម្បត្តិ ហើយនិងផលដំបូង ពីសេចក្តីចម្រើនរបស់ឯងទាំងអម្បាលម៉ានចុះ 10យ៉ាងនោះ អស់ទាំងជង្រុកឯងនឹងបានពេញបរិបូរ ឯអស់ទាំងធុងឯង នឹងបានទឹកទំពាំងបាយជូរហូរហៀរផង» (សុភាសិត ៣:៩-១០)។

៥. ការផ្សាភ្ជាប់រវាងបទគម្ពីរ និងបរិបទ
និយមន័យ: ក្រុមជំនុំដែលមានសុខភាពល្អ គិតពិចារណាអំពីបរិបទរបស់ខ្លួន (ទីតាំងភូមិសាស្ត្រ កត្តាសង្គម និងសេដ្ឋកិច្ច វប្បធម៌...)។ ក្នុងកាលដែលសារនៃដំណឹងល្អអំពីព្រះយេស៊ូគ្រិស្តមិនផ្លាស់ប្តូរ នោះវិធីសាស្ត្រក្នុងការចែកចាយដំណឹងល្អ អាចមានការផ្លាស់ប្តូរ។

«គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេសម្រាប់នឹងធ្វើការល្អគ្រប់មុខ» (២ ធីម៉ូថេ ៣:១៦-១៧)។

ការដឹកនាំ – ព្រះជាម្ចាស់ – កន្លែង – អ្នកដើរតាម - ឱកាស – ការទទួលខុសត្រូវ – ការរៀបចំ – ទុកចិត្ត – រូបកាយ – អំណោយទាន – ក្រុមជំនុំ – សហគមន៍ – ក្រុមជំនុំ – អំណោយទានខាងវិញ្ញាណ – ទេពកោសល្យ – អំណោយទាន – ចាប់អារម្មណ៍ – ព័ន្ធកិច្ច – ការបម្រើ – របៀប – ការកែសម្រួល

**តួនាទីប្រាំរបស់ក្រុមជំនុំដែលមានសុខភាពល្អ (១៥ នាទី)**

១. ការផ្សាយដំណឹងល្អ
និយមន័យ: ក្រុមជំនុំប្រកាសដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្ត តាមពាក្យសំដី និងការប្រព្រឹត្ត ហើយអញ្ជើញមនុស្សឲ្យមានចំណែកនៅក្នុងព្រះរាជ្យរបស់ព្រះ» កិច្ចការ ១:៨។

«ព្រះអម្ចាស់បានបន្ថែមចំនួនអ្នកដែលកំពុងតែបានសង្គ្រោះមកក្នុងក្រុមជំនុំជារៀងរាល់ថ្ងៃ។» (កិច្ចការ ២:៤៧)

២. ការបង្កើតសិស្ស
និយមន័យ: ក្រុមជំនុំជួយមនុស្សឲ្យមើលឃើញព្រះជាម្ចាស់ច្បាស់ និងស្គាល់បំណងព្រះហឫទ័យរបស់ព្រះសម្រាប់ជីវិតរបស់ពួកគេ ហើយបំពាក់បំប៉នពួកគេឲ្យដើរតាមព្រះអង្គក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិត។ ២ ពេត្រុស ៣:១៨

«អ្នកទាំងនោះក៏នៅតែព្យាយាមក្នុងសេចក្តីបង្រៀនរបស់ពួកសាវក ...» (កិច្ចការ ២:៤២)។

C ទាំងបួននៃភាពជាសិស្ស:
១. Conduct ការប្រព្រឹត្ត
២. Character អត្តចរិត
៣. Content ចិត្តរីករាយនឹងដំណឹងល្អ
៤. Commitment ការប្តូរផ្តាច់

៣. ការបម្រើ
និយមន័យ: ក្រុមជំនុំនិយាយពីសេចក្តីត្រូវការរបស់មនុស្សក្នុងព្រះនាមព្រះគ្រិស្ត ហើយអញ្ជើញពួកគេឲ្យធ្វើជាសិស្សរបស់ព្រះអង្គ។

«គេក៏លក់ទ្រព្យសម្បត្តិ និងរបស់គេទាំងប៉ុន្មាន ចែកដល់គ្នាតាមដែលគ្រប់គ្នាត្រូវការ...បណ្តាជនទាំងអស់គ្នាក៏រាប់អានគេ...» (កិច្ចការ ២:៤៥, ៤៧)។

ធនធាន – ភាពជាអ្នកមើលខុសត្រូវ – ទ្រព្យសម្បត្តិ – ធនធាន – របស់របរ – ក្រុមជំនុំ – សហគមន៍ – អត្ថបទ – បរិបទ –សារ – វិធីសាស្ត្រ – ការផ្សាយដំណឹងល្អ – ការប្រកាស – ពាក្យសម្តី – ការប្រព្រឹត្ត – អញ្ជើញ – ការបង្កើតសិស្ស – ព្រះជាម្ចាស់ – បំណងព្រះហឫទ័យ – បំពាក់បំប៉ន – ទាំងអស់ – ការប្រព្រឹត្ត – អត្តចរិត – ចិត្តរីករាយ - ការប្តូរផ្តាច់

*ទំនាក់ទំនងបីប្រភេទ រវាងការបម្រើ និងការផ្សាយដំណឹងល្អ*

I. ព័ន្ធកិច្ចជា **លទ្ធផល** ដែលកើតចេញពីការផ្សាយដំណឹងល្អ: ការប្រែចិត្តជឿដល់ព្រះគ្រិស្តធ្វើឲ្យយើងយកចិត្តទុកដាក់ ហើយមានចិត្តចង់បំពេញសេចក្តីត្រូវការរបស់អ្នកឯទៀត។
II. ព័ន្ធកិច្ចជា **ស្ពាន** សម្រាប់ការផ្សាយដំណឹងល្អ: ការបម្រើអ្នកដទៃ ជាចំណុចចាប់ផ្តើមដែលក្រោយមកធ្វើឲ្យពួកគេព្រមស្តាប់ដំណឹងល្អ។
III. ព័ន្ធកិច្ច **ដើរអមជាមួយនឹង** ការផ្សាយដំណឹងល្អ: និយាយអំពីព្រះយេស៊ូ ក្នុងពេលដែលកំពុងបម្រើអ្នកដទៃ។

៤. ការប្រកបគ្នា
និយមន័យ: សមាជិកជួយចែករំលែកបន្ទុកគ្នាទៅវិញទៅមក ដោយបង្ហាញចេញសេចក្តីស្រឡាញ់ និងចិត្តអាណិតអាសូររបស់ព្រះគ្រិស្ត។

«អ្នកទាំងនោះក៏នៅតែព្យាយាម... ក្នុងសេចក្តីប្រកបគ្នា...ពួកអ្នកដែលជឿទាំងប៉ុន្មាន ក៏នៅជា

មួយគ្នា ហើយមានរបស់ទាំងអស់នៅមូលព្រមគ្នា...រាល់តែថ្ងៃ គេនៅតែព្យាយាមក្នុងព្រះវិហារ ដោយមានចិត្តព្រមព្រៀងគ្នា ឯកាលនៅផ្ទះ ក៏កាច់នំបុ័ង ហើយបរិភោគអាហារដោយអំណរ និងចិត្តស្មោះត្រង់...» (កិច្ចការ ២:៤២, ៤៤, ៤៦)។

៥. <u>ការថ្វាយបង្គំ</u>
និយមន័យ: ក្រុមជំនុំជួបជុំគ្នាក្នុងនាម<u>គ្រួសារ</u>ព្រះ ដើម្បីជួបជាមួយព្រះវរបិតាក្នុង<u>ការថ្វាយបង្គំ</u> <u>ការលន់តួ</u> <u>ការអរព្រះគុណ</u> ក៏ដូចជាការប្តូរផ្តាច់ចំពោះ<u>ការបម្រើ</u> និង<u>ការអធិស្ឋាន</u>។

«អ្នកទាំងនោះក៏នៅតែព្យាយាម... ក្នុងសេចក្តីប្រកបគ្នា ព្រមទាំងការកាច់នំបុ័ង និងសេចក្តីអធិស្ឋានផង...ព្រមទាំងសរសើរដល់ព្រះ...» (កិច្ចការ ២:៤២, ៤៧)

*សកម្មភាពក្រុមតូច: ខ្ញុំនឹកចាំពេលដែល... (១០ នាទី)*

កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល: សកម្មភាពនេះមានគោលបំណងផ្តល់ឲ្យសិក្ខាកាមមានឱកាសឆ្លុះបញ្ចាំងអំពីបទពិសោធន៍មុនៗ ហើយប្រៀបធៀបបទពិសោធន៍ទាំងនោះជាមួយនឹងការរៀនថ្មី។

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

ការបម្រើ – សេចក្តីត្រូវការ – នាម – អញ្ជើញ – សិស្ស – លទ្ធផល – ស្ពាន – អមជាមួយ – ការប្រកបគ្នា – បន្ទុក – សេចក្តីស្រឡាញ់ – ចិត្តអាណិតអាសូរ – ការថ្វាយបង្គំ – គ្រួសារ – ការថ្វាយបង្គំ – ការលន់តួ – ការអរព្រះគុណ – ការបម្រើ - ការអធិស្ឋាន

- ចូរបំបែកក្រុមធំឲ្យទៅជាក្រុមតូចៗ ដែលក្រុមនីមួយៗមានគ្នា ៣ ឬ ៤នាក់។ ចូរសុំឲ្យម្នាក់ៗនៅក្នុងក្រុមតូចចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន ទាក់ទងនឹងលក្ខណៈមួយរបស់ក្រុមជំនុំដែលមានសុខភាពល្អ ឬក្រុមជំនុំដែលមិនមានសុខភាពល្អ។ ចូរសុំឲ្យម្នាក់ៗនៅក្នុងក្រុមបំពេញល្បះទាំងនេះ គឺខ្ញុំចាំថា ពេលដែល (ដាក់ឈ្មោះបទពិសោធន៍) បានកើតឡើង នោះធ្វើឲ្យខ្ញុំមានអារម្មណ៍ (ដាក់ឈ្មោះអារម្មណ៍) ដូច្នេះខ្ញុំ (ដាក់ឈ្មោះវិធានការ ដោយព្រោះតែបទពិសោធន៍នោះ) ពីព្រោះ (មូលហេតុដែលលោកអ្នកបានចាត់វិធានការ)។

ឧទាហរណ៍អំពីបទពិសោធន៍ក្រុមជំនុំដែលមានសុខភាពល្អ: ខ្ញុំចាំថា ពេលដែលគ្រូគង្វាលខ្ញុំបានចំណាយពេលបង្ហាត់បង្រៀនខ្ញុំ នោះធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំសំខាន់ចំពោះគាត់ និងចំពោះក្រុមជំនុំ ដូច្នេះខ្ញុំបានស្ម័គ្រចិត្តបង្រៀនសមាជិកថ្មី ពីព្រោះខ្ញុំចង់ឲ្យសមាជិកថ្មីដឹងថា ពួកគេក៏សំខាន់ចំពោះក្រុមជំនុំដែរ។

ឧទាហរណ៍អំពីបទពិសោធន៍ក្រុមជំនុំដែលមិនមានសុខភាពល្អ: ខ្ញុំចាំថា ពេលខ្ញុំចូលទៅលេងក្រុមជំនុំមួយនៅក្នុងសហគមន៍របស់ខ្ញុំ គ្មាននរណាម្នាក់ស្វាគមន៍ខ្ញុំសោះ បែបនោះធ្វើឲ្យខ្ញុំមានអារម្មណ៍ថា គ្មាននរណាខ្វល់អំពីខ្ញុំទេ ដូច្នេះខ្ញុំក៏ឈប់ទៅក្រុមជំនុំនោះទៀត ពីព្រោះខ្ញុំចង់នៅក្នុងក្រុមជំនុំណាដែលយកចិត្តទុកដាក់ចំពោះមនុស្សគ្រប់គ្នា។

*នេះជារូបមន្តមួយដែលមានទម្រង់សាមញ្ញ: ខ្ញុំចាំថា ពេល ____________________ នោះធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ____________________។ ដូច្នេះខ្ញុំ ____________________ ពីព្រោះ ____________________។*

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ក្រោយពីគ្រប់គ្នានៅក្នុងក្រុមបានចែកចាយបទពិសោធន៍របស់ខ្លួនរួចហើយ ចូរឲ្យក្រុមពិភាក្សាគ្នាអំពីរបៀបដែលបទពិសោធន៍ទាំងនោះពាក់ព័ន្ធនឹងលក្ខណៈទាំង ១០ របស់ក្រុមជំនុំដែលមានសុខភាពល្អ ដែលពួកគេទើបតែបានរៀន។

- ជាចុងក្រោយ ចូរបញ្ចប់ម៉ោងសិក្សានេះដោយនិយាយថាៈ «នៅក្នុងការសិក្សាដែលមាន ១២ ម៉ូឌុលនេះ លោកអ្នកនឹងរៀនអំពីរបៀបអនុវត្តលក្ខណៈនីមួយៗក្នុងចំណោមលក្ខណៈទាំង ១០ នៅក្នុងការងាររបស់លោកអ្នក ក្នុងនាមជាអ្នកដាំក្រុមជំនុំ ដើម្បីឲ្យនៅទីបញ្ចប់ លោកអ្នកនឹងអបអរជាមួយគ្នាអំពីការចាប់កំណើតឡើងរបស់ក្រុមជំនុំដែលមានសុខភាពល្អ!»។

សម្រាក (១៥ នាទី)

# ម៉ោងទី ២
# តើអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អមានន័យដូចម្តេច? (៦០ នាទី)

កត្តាចង្អុលបង្ហាញប្រាំយ៉ាងអំពីអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អ (៤០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា: «ដើម្បីដាំក្រុមជំនុំដែលមានសុខភាពល្អ អ្នកដាំក្រុមជំនុំត្រូវតែមានសុខភាពល្អ។ នៅក្នុងម៉ោងនេះ យើងនឹងរៀនអំពីកត្តាចង្អុលបង្ហាញទាំងប្រាំ អំពីអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អ»។

- ចូរសុំសិក្ខាកាមឲ្យបំពេញក្រាហ្វិចនៅក្នុងសៀវភៅលំហាត់របស់ពួកគេ នៅពេលដែលលោកអ្នកចែកចាយព័ត៌មាន។
- ចូរចាប់ផ្តើមជាមួយនឹង «ព្រះបានត្រាស់ហៅ» ហើយបន្តតាមទ្រនិចនាឡិកាជុំវិញក្រាហ្វិច។




ត្រូវបានត្រាស់ហៅ - ជំនឿ - ប្តី ឬប្រពន្ធ - មាននិមិត្ត - ច្បាស់លាស់ - សង់ - មានទំនាក់ទំនង - សម្រួលឲ្យត្រូវតាម - បត់បែន - ប្តូរផ្តាច់ - គ្រប់ជ្រុងជ្រោយ - ខាងវិញ្ញាណ - សរីរាង្គ - ស្វ័យគុណ - លើកស្ទួយ

# ការវាយតម្លៃកម្រិតទំនុកចិត្តរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ (២០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួលៈ សកម្មភាពនេះមានគោលបំណងជួយអ្នកដាំក្រុមជំនុំ គិតអំពីបទពិសោធន៍របស់ខ្លួនកាលពីមុន ពាក់ព័ន្ធនឹងគំរូអ្នកដាំក្រុមជំនុំ ដែលមានសុខភាពល្អ។

- ចូរសុំឲ្យសិក្ខាកាមបំពេញការវាយតម្លៃខ្លួនឯងនៅខាងក្រោម និងផែនការសម្រាប់កសាង ទំនុកចិត្ត។

*ចូរបំពេញការវាយតម្លៃខាងខ្លួនឯងខាងក្រោម ដោយគូសកម្រិតទំនុកចិត្តណាមួយដែលលោកអ្នកមានទាក់ទងនឹងសេចក្តីដែលប្រយោគនីមួយៗពណ៌នាប្រាប់។*

ដោយផ្អែកលើអាកប្បកិរិយា និងបទពិសោធន៍កាលពីមុនរបស់ខ្ញុំ ក្នុងនាមជាអ្នកដាំក្រុមជំនុំ...

១- ខ្ញុំនឹងអនុវត្តជំនឿរបស់ខ្ញុំឲ្យបានខ្ជាប់ខ្ជួន និងរក្សាឲ្យនៅតែមានជីវិតរឹងមាំជាមួយ

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

ព្រះ។

២- ខ្ញុំនឹងលើកទឹកចិត្តខ្លួនឯង និងធ្វើការដោយមិនបាច់មានអ្នកមើលពីលើ។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

៣- ខ្ញុំមានការគាំទ្រពីប្តី ឬប្រពន្ធរបស់ខ្ញុំ។

៤- ខ្ញុំអាចស្រមៃឃើញរូបភាពច្បាស់អំពីពេលអនាគតទាក់ទងនឹងការដាំក្រុមជំនុំដែលមាន

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

សុខភាពល្អ

៥- ខ្ញុំមានសមត្ថភាពកសាងក្រុមដែលអាចសម្រេចរូបភាពនៅពេលអនាគតនោះបាន។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

៦- ខ្ញុំនឹងសម្របយ៉ាងល្អឲ្យត្រូវទៅនឹងបរិបទរបស់ខ្ញុំក្នុងការដាំក្រុមជំនុំ។

៧- ខ្ញុំនឹងសង់ទំនាក់ទំនងល្អនៅក្នុងសហគមន៍។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

៨- ខ្ញុំនឹងបត់បែនក្នុងការដោះស្រាយជាមួយមនុស្ស និងកាលៈទេសៈ។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

៩- ខ្ញុំនឹងដឹកនាំក្រុមជំនុំថ្មីឲ្យរីកចម្រើនឡើងខាងវិញ្ញាណ។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

១០- ខ្ញុំនឹងដឹកនាំក្រុមជំនុំថ្មីឲ្យរីកចម្រើនឡើងជាស្ថាប័នមួយដ៏មានប្រសិទ្ធភាព

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

(ខាងសរីរាង្គ)។

១១- ខ្ញុំនឹងដឹកនាំក្រុមជំនុំឲ្យរីកចម្រើនឡើងខាងបរិមាណ ដោយឈោងចាប់សហគមន៍តាមរយៈសមាជិកក្រុមជំនុំ។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

១២- ខ្ញុំនឹងបង្កើតឱកាសដ៏មានអត្ថន័យសម្រាប់ការប្រកបគ្នា ឲ្យមានចំនួនគ្រប់គ្រាន់។

១៣- ខ្ញុំនឹងដោះស្រាយជម្លោះតាមរបៀបមួយដែលមានសុខភាពល្អ។

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

១៤- ខ្ញុំនឹងឲ្យអ្នកដទៃទៀតចូលរួមនៅក្នុងព័ន្ធកិច្ច។

១៥- ខ្ញុំនឹងជួយអ្នកដទៃឲ្យរកឃើញអំណោយទាន ហើយប្រើអំណោយទានខាងវិញ្ញាណ

☐ ទំនុកចិត្តទាប ☐ ទំនុកចិត្តខ្លះ ☐ ទំនុកចិត្តខ្ពស់

របស់ខ្លួន។

# ផែនការរបស់ខ្ញុំសម្រាប់សង់ទំនុកចិត្ត

១. តើផ្នែកទី ១ ដែលខ្ញុំត្រូវសង់ទំនុកចិត្តនៅពេលឥឡូវនេះ ជាអ្វី?

២. តើវិធានការដែលខ្ញុំអាចធ្វើភ្លាម ដើម្បីជួយខ្ញុំសង់ទំនុកចិត្តនៅក្នុងផ្នែកនេះ ជាអ្វី?

៣. ចូរសង្កេតមើលផ្នែកដែលលោកអ្នកមានទំនុកចិត្តខ្ពស់។ ទាំងនេះទំនងជាចំណុចខ្លាំងរបស់លោកអ្នកក្នុងនាមជាអ្នកដាំក្រុមជំនុំ។ តើលោកអ្នកអាចចាត់វិធានការអ្វីបាន ដើម្បីទាញយកប្រយោជន៍ជាអតិបរិមាភ្លាមៗចេញពីចំណុចទាំងនេះ ក្នុងការខិតខំប្រឹងប្រែងដាំក្រុមជំនុំ។

៤. តើខ្ញុំស្គាល់អ្នកណាដែលខ្ញុំអាចសុំឲ្យគាំទ្រខ្ញុំក្នុងការអធិស្ឋាន ហើយជាអ្នកដែលខ្ញុំត្រូវរៀបរាប់ប្រាប់ នៅពេលដែលខ្ញុំប្រឹងប្រែងសង់ទំនុកចិត្ត ហើយទាញយកប្រយោជន៍ឲ្យបានច្រើនបំផុត ចេញពីចំណុចខ្លាំងរបស់ខ្ញុំ?

____________________________________________________________

____________________________________________________________

____________________________________________________________

_______________________

____________________________________________________________

________

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរសុំឲ្យសិក្ខាកាមចាប់ដៃគូ ឬចូលជាក្រុមដែលមានគ្នា ៣ នាក់ ហើយចែកចាយអ្វីដែលពួកគេបានរៀនអំពីខ្លួនឯងតាមរយៈម៉ោងនេះ និងតាមរយៈការវាយតម្លៃខ្លួនឯង ព្រមទាំងសកម្មភាពអ្វីខ្លះដែលពួកគេមានផែនការនឹងចាប់ផ្តើម ពាក់ព័ន្ធនឹងអ្វីដែលពួកគេបានរៀន។
- ចូរបញ្ចប់ម៉ោងនេះដោយសុំឲ្យដៃគូ ឬសមាជិកក្នុងក្រុមនីមួយៗអធិស្ឋានឲ្យគ្នាទៅវិញទៅមក។

ការណែនាំអំពីសកម្មភាពបន្ថែម:

- ចូរប្រើពិន្ទុការវាយតម្លៃខ្លួនឯងខាងក្រោម ដើម្បីជួយសិក្ខាកាមឲ្យយល់កាន់តែស៊ីជម្រៅថែមទៀតអំពីបទពិសោធន៍របស់ពួកគេ ទាក់ទងនឹងគំរូអ្នកដាំក្រុមជំនុំដែលមានសុខភាពល្អ។

សន្លឹកពិន្ទុការវាយតម្លៃកម្រិតទំនុកចិត្តរបស់ខ្ញុំសម្រាប់ការដាំក្រុមជំនុំ *

| ទំនុកចិត្តទាប | ទំនុកចិត្តខ្លះ | ទំនុកចិត្តខ្ពស់ | ពិន្ទុសរុប |
|---|---|---|---|
| នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរលេខសំណួរនីមួយៗដែលលោកអ្នកបានឆ្លើយថា «ទំនុកចិត្តទាប»។ ឧទាហរណ៍ ១, ៦, ៧ | នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរលេខសំណួរនីមួយៗដែលលោកអ្នកបានឆ្លើយថា «ទំនុកចិត្តខ្លះ»។ ឧទាហរណ៍ ២, ៨, ១០ | នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរលេខសំណួរនីមួយៗដែលលោកអ្នកបានឆ្លើយថា «ទំនុកចិត្តខ្ពស់»។ ឧទាហរណ៍ ៣, ១១, ១៥ | |
| | | | |
| នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរចំនួនសរុបនៃសំណួរដែលលោកអ្នកបានឆ្លើយថា: «ទំនុកចិត្តទាប»។ ឧទាហរណ៍ប្រសិនបើលោកអ្នកឆ្លើយបីសំណួរថា: «ទំនុកចិត្តទាប» ចូរសរសេរ «៣» នៅក្នុងប្រអប់ | នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរចំនួនសរុបនៃសំណួរដែលលោកអ្នកបានឆ្លើយថា: «ទំនុកចិត្តខ្លះ» ហើយគុណចំនួននឹង២។ ឧទាហរណ៍ប្រសិនបើលោកអ្នកឆ្លើយបីសំណួរថា: «ទំនុកចិត្តខ្លះ» ចូរយក ៣ x ២ ហើយសរសេរ «៦» នៅក្នុងប្រអប់។ | នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរចំនួនសរុបនៃសំណួរដែលលោកអ្នកបានឆ្លើយថា: «ទំនុកចិត្តខ្ពស់» ហើយគុណចំនួននឹង៣។ ឧទាហរណ៍ប្រសិនបើលោកអ្នកឆ្លើយបីសំណួរថា: «ទំនុកចិត្តខ្ពស់» ចូរយក ៣ x ៣ ហើយសរសេរ «៩» នៅក្នុងប្រអប់។ | នៅក្នុងប្រអប់ខាងក្រោម ចូរសរសេរផលបូកទំនុកចិត្តទាប +ទំនុកចិត្តខ្លះ+ ទំនុកចិត្តខ្ពស់។ ឧទាហរណ៍ ប្រសិនបើលោកអ្នកមានពិន្ទុ តិច = ៣ ខ្លះ = 6 និងខ្ពស់ = ៩ នោះពិន្ទុសរុបរបស់លោកអ្នកគឺ ៣+៦+៩ = ១៨ |
| | | | |

ចន្លោះពិន្ទុ:

ពិន្ទុសរុបសម្រាប់ទំនុកចិត្តទាប ១៥-២៥

ពិន្ទុសរុបសម្រាប់ទំនុកចិត្តខ្លះ ២៦-៣៥
ពិន្ទុសរុបសម្រាប់ទំនុកចិត្តខ្ពស់ ៣៦-៤៦

- ចូរពិនិត្យមើលសំណួរដែលលោកអ្នកបានដាក់ចូលក្រុមជាមួយគ្នា នៅក្នុងកម្រិតទំនុកចិត្តទាំងបី។ តើលោកអ្នករកឃើញគំរូណាមួយក្នុងចំណោមសំណួរទាំងនេះឬទេ?
- ចូរពិចារណាពិន្ទុកម្រិតទំនុកចិត្តសរុបរបស់លោកអ្នក។ តើការដាក់កម្រិតទំនុកចិត្តទាំងបីចូលគ្នា រួមចំណែកដល់ពិន្ទុសរុបរបស់លោកអ្នកយ៉ាងដូចម្ដេច? តើការនេះប្រាប់អ្វីដល់លោកអ្នកពាក់ព័ន្ធនឹងភាពត្រៀមជាស្រេចរបស់លោកអ្នកក្នុងការដាំក្រុមជំនុំ?

*សូមកត់សម្គាល់ថា ការវាយតម្លៃខ្លួនឯងនេះ គឺជាឧបករណ៍មួយដែលជួយអ្នកដាំក្រុមជំនុំ ឲ្យឆ្លុះបញ្ចាំងអំពីភាពត្រៀមជាស្រេចរបស់អ្នកនោះ សម្រាប់ការងារដាំក្រុមជំនុំ។ ឧបករណ៍នេះ មិនមែនជាអ្នកទស្សន៍ទាយអំពីជោគជ័យ ឬបរាជ័យ ក្នុងនាមជាអ្នកដាំក្រុមជំនុំទេ។ ផ្ទុយទៅវិញ ឧបករណ៍នេះបើកទ្វារសម្រាប់ការឆ្លុះបញ្ចាំងអំពីខ្លួនឯង និងការពិភាក្សារកផលផ្លែជាមួយអ្នកដាំក្រុមជំនុំដូចគ្នា ជាមួយអ្នកសម្របសម្រួលក្នុងការដាំក្រុមជំនុំ ជាមួយគ្រូឧបជ្ឈា ឬជាមួយអ្នកមើលខុសត្រូវ។

# ម៉ោងទី ៣
# ការគិត "អ": តើព្រះជាម្ចាស់ចង់បានអ្វី? (៦០ នាទី)

## តើការគិត "អ" ជាអ្វី? (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា: តើការគិត "អ" ជាអ្វី?"

"អ" គឺជាលទ្ធផលចុងក្រោយនៃអ្វីដែលព្រះជាម្ចាស់ចង់បានសម្រាប់ប្រទេសមួយ តំបន់មួយ ទីក្រុងមួយ ភូមិមួយ ឬសហគមន៍មួយ។ "អ" ត្រូវបានគេប្រើ ពីព្រោះតួអក្សរនេះ ស្ថិតនៅខាងចុងនៃព្យញ្ជនៈភាសាខ្មែរ ក៏ដូចជាតួអក្សរអូមេហ្គា ដែលស្ថិតនៅក្នុងតួអក្សរក្រិកដូច្នោះដែរ។

ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរសុំសិក្ខាកាមផ្សេងៗគ្នាឲ្យអានអេសាយ ១១:៩ អេសាយ ៦៥:១២-២៥ និងវិវរណៈ ២១:១-៤, ២២-២៧, ២២:១-៥។

ចូរអាន:

អេសាយ ១១:៩, ៦៥:១២-២៥ វិវរណៈ ២១:១-៤, ២២-២៧, ២២:១-៥

ចូរឆ្លុះបញ្ចាំង:
- តើអត្ថបទគម្ពីរទាំងនេះពណ៌នាអំពី«ចុងបញ្ចប់»យ៉ាងដូចម្ដេច (ចុងបញ្ចប់ដែលព្រះជាម្ចាស់ចង់បាន)?
- តើការផ្ដោតតែទៅលើស្ថានសួគ៍ ហើយមិនផ្ដោតលើផែនដី មានគ្រោះថ្នាក់ដូចម្ដេច?

ចូរអាន:

ម៉ាកុស ១៣:១០ ម៉ាថាយ ២៤:១៤ យ៉ូហាន ៣:១៦
១ ធីម៉ូថេ ២:៣-៤ លូកា ២៤:៤៥-៤៧ ២ ពេត្រុស ៣:៩
កូឡុស ១:៦ ២ កូរិនថូស ៥:៩

ចូរឆ្លុះបញ្ចាំង:
- តើខគម្ពីរទាំងនេះប្រាប់យើងដូចម្ដេចអំពីផែនការរបស់ព្រះ សម្រាប់ការឈោងចាប់ដោយដំណឹងល្អ?

លទ្ធផលចុងក្រោយ

- តើរបៀបណាខ្លះដែលព្រះជាម្ចាស់សម្រេចបានលទ្ធផលចុងក្រោយដែលព្រះអង្គចង់បាន?
- តើឧបករណ៍ទីមួយដែលព្រះជាម្ចាស់ប្រើក្នុងការសម្រេចលទ្ធផលចុងក្រោយដែលព្រះអង្គ ចង់បាន ជាអ្វី?
- តើមានមធ្យោបាយផ្សេងទៀតដែលព្រះជាម្ចាស់កំពុងប្រើ កាន់តែមានប្រសិទ្ធភាពសម្រាប់សព្វថ្ងៃនេះដែរឬទេ?

ចូរអាន:

ម៉ាថាយ ២៨:១៨-២០ កិច្ចការ ១:៨ អេភេសូរ ៣:១០

ចូរឆ្លុះបញ្ចាំង:
- តើខគម្ពីរទាំងនេះប្រាប់យើងដូចម្ដេចអំពីកិច្ចការរបស់យើងក្នុងការសម្រេចបំណងប្រាថ្នារបស់ព្រះ សម្រាប់ពិភពលោក?

ជំហានសំខាន់ៗខ្លះដើម្បីទៅដល់ "អ" (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរចែកសិក្ខាកាមទៅជាក្រុមដែលមានគ្នា ៣ ឬ ៤ នាក់។
- ចូរសុំឲ្យមនុស្សនៅក្នុងក្រុមនីមួយៗ អានព្រះគម្ពីរដែលពាក់ព័ន្ធប្រធានបទមួយ ក្នុងចំណោមប្រធានបទ ៥ ខាងក្រោម ហើយពិភាក្សាសំណួរដែលពាក់ព័ន្ធនៅក្នុងក្រុមរបស់ពួកគេ។
- ១០ នាទីក្រោយមក ឲ្យក្រុមនីមួយៗមានពេលមួយនាទី ដើម្បីចែកចាយដោយសង្ខេបអំពីចំណុចសំខាន់ៗដែលពួកគេបានពិភាក្សា។

ក. ការអធិស្ឋាន | ២ របាក្សត្រ ៧:១៤, ម៉ាថាយ ៩:៣៨
តើយើងគួរតែអធិស្ឋានសូមអ្វី នៅក្នុងការខំប្រឹងប្រែងរបស់យើងដើម្បីសម្រេចបាន «អ»?

ខ. សេចក្តីស្រឡាញ់ និងការរួបរួមគ្នា | យ៉ូហាន ១៣:៣៥, យ៉ូហាន ១៧:២០-២៣
ហេតុអ្វីបានជាសេចក្តីស្រឡាញ់ និងការរួបរួមគ្នាសំខាន់ចំពោះការសម្រេចបាន «អ»?

គ. និមិត្ត | យ៉ូហាន ៣:១៦, ១ យ៉ូហាន ២:២, ម៉ាថាយ ៩:៣៧
តើខគម្ពីរទាំងនេះប្រាប់យើងដូចម្តេចអំពីនិមិត្តរបស់ព្រះ?

ឃ. ការផ្សាយដំណឹងល្អ | រ៉ូម ១០:១៤-១៥
តើយើងអាចរកបានឱកាសដើម្បីធ្វើបន្ទាល់ប្រាប់អ្នកមិនជឿនៅក្នុងតំបន់របស់យើងបានដោយរបៀបណា? តើអ្នកជឿទៅឲ្យហួសមិត្តភក្តិដែលជាអ្នកជឿ ហើយឈោងចាប់អ្នកមិនជឿបានយ៉ាងដូចម្តេច?

ង. ការដាំក្រុមជំនុំ | អេភេសូរ ៣:៨-១១, អេភេសូរ ៤:១១-១៣
តើព្រះជាម្ចាស់ចង់ឲ្យប្រជារាស្ត្ររបស់ព្រះអង្គធ្វើអ្វី?

នៅពេលដែលក្រុមជំនុំថ្មីត្រូវបានដាំ មនុស្សត្រូវបានឈោងចាប់នៅក្នុងសហគមន៍ដែលនៅជុំវិញ ជាកន្លែងដែលដំណឹងល្អមិនបានទៅដល់ ហើយគ្មានក្រុមជំនុំថ្មី។ តើហេតុផលអ្វីខ្លះបានជាការនេះកើតឡើង? ប្រសិនបើលោកអ្នកដឹងអំពីករណីបែបនេះកើតឡើង ចូរប្រាប់ក្រុមរបស់លោកអ្នកអំពីរឿងនោះ ហើយពិភាក្សាគ្នាអំពីអ្វីដែលបានកើតឡើង។

ការគិត "អ" ជាលទ្ធផលនាំឲ្យមានសកម្មភាព "អ" (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា: «សកម្មភាពដែលជាលទ្ធផល កើតចេញពីការគិត «អ» គឺជា<u>ការរៀបចំផែនការ</u> «អ» និង<u>ការថ្វាយ</u> «អ»»។ ចូរពិភាក្សាសំណួរខាងក្រោមដោយសង្ខេប។

១. តើសំណួរយុទ្ធសាស្ត្រមួយចំនួនដែលត្រូវតែឆ្លើយដើម្បីឲ្យការដាំក្រុមជំនុំកើតឡើង មានអ្វីខ្លះ?
២. តើផែនការមួយចំនួនដែលត្រូវធ្វើ នៅពេលដែលក្រុមជំនុំមួយរីកចម្រើនឡើងឆ្ពោះទៅរកការដាំក្រុមជំនុំថ្មី មានអ្វីខ្លះ?

ផែនការសកម្មភាពសម្រាប់ម៉ូឌុល ២: ផែនការ "អ" របស់លោកអ្នក (១៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- អានលំហាត់ខាងក្រោមជាមួយសិក្ខាកាម។
- បញ្ជាក់ប្រាប់ថា លទ្ធផលរបស់លំហាត់នេះនឹងត្រូវបានចែកចាយជាមួយក្រុមនៅក្នុង ម៉ូឌុល ២។
- ចំណាយពេលឆ្លើយសំណួរក្នុងលំហាត់ទាំងអស់។

**លំហាត់:**

១. ចូររៀបចំ ឬរកផែនទីក្រុង ឬភូមិរបស់លោកអ្នក ដែលលោកអ្នកមានគម្រោងនឹងដាំក្រុមជំនុំ។ ចូររកឲ្យឃើញក្រុមជំនុំដំណឹងល្អឲ្យបានច្រើន តាមដែលលោកអ្នកអាចរកឃើញនៅក្នុងក្រុង ឬក្នុងភូមិរបស់លោកអ្នក ហើយបង្ហាញប្រាប់ទំហំប្រហាក់ប្រហែលរបស់ក្រុមជំនុំទាំងនោះ នៅលើផែនទី។ ចូរស្វែងរកព័ត៌មានអំពីចំនួនប្រជាជនសរុបនៅក្នុងទីក្រុង ឬក្នុងភូមិនោះ។

ការរៀបចំផែនការ

អ្នកដឹកនាំគ្រិស្តបរិស័ទបាននិយាយថា ដើម្បីឲ្យប្រទេសមួយមានក្រុមជំនុំ«ជ្រួតជ្រាប» គឺត្រូវតែមានក្រុមជំនុំដំណឹងល្អមួយ សម្រាប់មនុស្ស ១០០០ នាក់។ ប្រសិនបើយើងទទួលយកគំនិតដែលថា គួរតែមានក្រុមជំនុំមួយសម្រាប់មនុស្ស ១០០០ នាក់ តើលោកអ្នកគិតថាត្រូវដាំក្រុមជំនុំប៉ុន្មានទៀត នៅក្នុងទីក្រុង ឬភូមិដែលលោកអ្នកចង់ដាំ?

២. ចូរចាប់ផ្តើមគិតអំពីផែនការសម្រាប់ការប្រឹងប្រែងដាំក្រុមជំនុំ ដែលរួមទាំងការអធិស្ឋាន ការរួបរួម សេចក្តីស្រឡាញ់ និមិត្ត ការផ្សាយដំណឹងល្អ និងការដាំក្រុមជំនុំ។ ចូរកត់ត្រាគំនិតផ្តួចផ្តើមខ្លះៗ ហើយចែកចាយប្រាប់គ្រូឧបជ្ឈាររបស់លោកអ្នក ឬជាមួយគ្រូបង្វាត់នៅក្នុងម៉ោងសិក្សានេះ។

៣. ចូរគិតពីសហគមន៍ ភូមិ ទីក្រុង តំបន់ ឬប្រទេសរបស់លោកអ្នក។ ចូរពិចារណាចម្លើយរបស់លោកអ្នក សម្រាប់សំណួរទាំងនេះ ៖

- «តើព្រះជាម្ចាស់ចង់បានអ្វីសម្រាប់ _______________ (ឈ្មោះទីក្រុង ភូមិ ឬសហគមន៍ដែលលោកអ្នកមានគម្រោងដាំក្រុមជំនុំ)? ចូរសរសេរចម្លើយមួយកថាខណ្ឌ។
- ចូរកត់ត្រាការបីយ៉ាង ដែលលោកអ្នកនឹងធ្វើ ដើម្បីនឹងជួយឲ្យមើលឃើញ «អ» កើតឡើងនៅក្នុងតំបន់របស់លោកអ្នក។

ឆ្ពោះមកដល់ការថ្វាយ "អ" (១០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរសុំឲ្យសិក្ខាកាមអាន ២ កូរិនថូស ៨:៧, ២ កូរិនថូស ៩:៦-៧។
- ចូរពិភាក្សាសំណួរខាងក្រោម:

តើយើងអាចដឹងប្រាកដបានដូចម្តេចថា លុយដែលត្រូវការសម្រាប់ការដាំក្រុមជំនុំ នឹងត្រូវបានផ្គត់ផ្គង់?

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរចែកចាយគោលការណ៍ខាងក្រោម ដែលទាក់ទងទៅនឹងរឿងលុយកាក់សម្រាប់ក្រុមជំនុំដែលបានដាំ និងរបៀបរកលុយសម្រាប់ការដាំក្រុមជំនុំ។
- ចូរសុំសិក្ខាកាមឲ្យបំពេញត្រូវតាមកន្លែងនៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ចូរនិយាយថា: «មានគោលគំនិតសំខាន់ពីរ ពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញវត្ថុដល់ក្រុមជំនុំដែលបានដាំ»

គោលការណ៍ពីរក្នុងការផ្តល់ហិរញ្ញវត្ថុដល់ក្រុមជំនុំដែលបានដាំ

១. ទុកចិត្តព្រះជាម្ចាស់
២. ការស្តាប់ចិត្ត
ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរសុំឲ្យសិក្ខាកាមអានភីលីព ៤:៦-៧, ១១-១៣, ១៩ ហើយពិភាក្សាដោយសង្ខេបអំពីទំនាក់ទំនងរបស់ខគម្ពីរទាំងនោះ ជាមួយគោលការណ៍ទាំងពីរ។
- បន្ទាប់មក ចូរចែកចាយប្រាប់មនុស្សក្នុងថ្នាក់អំពីរបៀបខាងក្រោម ក្នុងការផ្តល់ហិរញ្ញវត្ថុដល់ក្រុមជំនុំដែលបានដាំ។

ចូរអាន:
ភីលីព ៤:៦-៧, ៤:១១-១៣, ៤:១៩

របៀបផ្តល់ហិរញ្ញវត្ថុដល់ក្រុមជំនុំថ្មីដែលបានដាំ

១. ការឧបត្ថម្ភពីក្រុមជំនុំមេ
២. ការឧបត្ថម្ភពីនិកាយ ក្រុមបេសកកម្ម ឬអង្គការ
៣. ក្រុមឧបត្ថម្ភពិសេស
៤. ការឧបត្ថម្ភពីអ្នកវិនិយោគ មិត្តភក្តិ និងសាច់ញាតិ
៥. ការឧបត្ថម្ភបានមកពីការលក់ទ្រព្យសម្បត្តិ
៦. ការឧបត្ថម្ភមកពីប្រាក់ខែទីពីរ នៅក្នុងគ្រួសារ
៧. ព័ន្ធកិច្ចបម្រើព្រះផង ធ្វើការងារក្រៅផង

អាហារថ្ងៃត្រង់ (៦០ នាទី)

ទុកចិត្តព្រះ - ការស្តាប់ចិត្ត -ក្រុមជំនុំមេ - និកាយ - បេសកកម្ម - អង្គការ - ពិសេស - អ្នកវិនិយោគ - មិត្តភក្តិ - សាច់ញាតិ

# មេរៀនទី ៤
# រង្វង់នៃការដាំក្រុមជំនុំ (៦០ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ដោយប្រើក្រាហ្វិចរង្វង់នៃការដាំក្រុមជំនុំខាងក្រោម ចូរពណ៌នាដោយសង្ខេបអំពីរង្វង់នៃការដាំក្រុមជំនុំ។

រង្វង់នៃការដាំក្រុមជំនុំ (៥ នាទី)




ការអធិស្ឋាន - ផ្សាយដំណឹងល្អ - បង្កើតសិស្ស - ជួបជុំគ្នា - អភិវឌ្ឍអ្នកដឹកនាំ - ពហុគុណ

សកម្មភាពក្រុមតូច (២៥ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរចែកជា ៧ ក្រុម (ក្រុមមួយសម្រាប់ដំណាក់កាលមួយ)។ ចូរបែងចែកដំណាក់កាលឲ្យក្រុម នីមួយៗ។
- ចូរសុំក្រុមឲ្យអានព្ទបទគម្ពីរពាក់ព័ន្ធនឹងដំណាក់កាលរបស់ពួកគេ។
- ចូរណែនាំក្រុមឲ្យបង្កើតសកម្មភាពឲ្យបានច្រើន តាមដែលអាចធ្វើបាន ដើម្បីដោះស្រាយ «សកម្មភាព» និង«បញ្ហាគន្លឹះ»ដែលពាក់ព័ន្ធនឹងដំណាក់កាលនីមួយៗ។

ដំណាក់កាលទី **I:** ការអធិស្ឋាន (លូកា ១០:២, អេភេសូរ ៦:១៨-១៩, កូឡុស ៤:២-៤)
សកម្មភាព:

- ចូរចាប់ផ្តើមដោយការអធិស្ឋាន។
- ចូររកទីតាំងក្រុមដែលលោកអ្នកនឹងផ្សាយដំណឹងល្អ ហើយដាំក្រុមជំនុំ។
- ចូរអធិស្ឋានរកពួកអ្នកដែលនឹងជួយ និងសម្រាប់លោកអ្នកផ្ទាល់។

បញ្ហាគន្លឹះ:

- តើវាលចម្រូតផ្ទាល់ខ្លួនរបស់ខ្ញុំជាអ្វី? តើព្រះជាម្ចាស់ចង់បានអ្វីពីខ្ញុំនៅក្នុងតំបន់របស់ខ្ញុំ?
- តើការត្រាស់ហៅ និងនិមិត្តដែលព្រះជាម្ចាស់ប្រទានឲ្យខ្ញុំ មានអ្វីខ្លះខុសពីការត្រាស់ហៅ និងនិមិត្តដែលព្រះអង្គប្រទានឲ្យអ្នកដទៃ?
- តើនរណានឹងជួយ?
- តើខ្ញុំគួរតែអធិស្ឋានសម្រាប់អ្នកណា? តើខ្ញុំគួរតែអធិស្ឋានសម្រាប់អ្វី?
- តើខ្ញុំគួរតែសុំព្រះជាម្ចាស់ឲ្យធ្វើអ្វីនៅក្នុងការបម្រើរបស់ខ្ញុំចំពោះព្រះអង្គ?

ដំណាក់កាលទី **II:** ផ្សាយដំណឹងល្អ (១ កូរិនថូស ៩:១៩-២៣ កិច្ចការ ១:៨)
សកម្មភាព:

- ទាក់ទងអ្នកដឹកនាំសំខាន់ៗ និងសង់ទំនាក់ទំនង
- ផ្សាយដំណឹងល្អដល់មនុស្សបាត់បង់
- ចាប់ផ្តើមក្រុមសិក្សាព្រះគម្ពីរបែបផ្សាយដំណឹងល្អ
- បង្ហាញអ្នកជឿថ្មី ពីរបៀបធ្វើព័ន្ធកិច្ចតាមរបៀបដែលគេមើលលោកអ្នកធ្វើ

បញ្ហាគន្លឹះ:

- តើវិធីសាស្ត្រផ្សាយដំណឹងល្អអ្វីខ្លះដែលមានប្រសិទ្ធភាពបំផុត សម្រាប់ឲ្យយើងឈានទៅដល់ គោលដៅរបស់យើង?
- តើយើងបង្កើតទំនាក់ទំនងជាមួយអ្នកដឹកនាំសំខាន់ៗយ៉ាងដូចម្តេច? តើពួកគេជានរណា?
- តើយើងរកពួកគេឃើញដោយរបៀបណា?
- តើយើងហ្វឹកហ្វឺនអ្នកជឿថ្មីឲ្យធ្វើបន្ទាល់ប្រាប់មិត្តភក្តិ និងគ្រួសាររបស់ពួកគេយ៉ាងដូចម្តេច?
- តើយើងដឹងថា មិត្តភក្តិរបស់អ្នកជឿថ្មីជានរណា ហើយចាប់ផ្តើមផ្សាយដំណឹងល្អឲ្យពួកគេបានដោយរបៀបណា?

ដំណាក់កាលទី **III:** បង្កើតសិស្ស (១ ថែស្សាឡូនីច ៥:១១, ម៉ាថាយ ២៨:១៨-២០)
សកម្មភាព:

- បង្រៀនអ្នកជឿថ្មី
- ធ្វើជាគ្រូឧបជ្ឈាដល់អ្នកដឹកនាំដែលកំពុងលេចធ្លោ
- បង្រៀនអំពីការស្តាប់បង្គាប់ និងការប្តូរផ្តាច់ចំពោះព្រះអម្ចាស់
- លើកទឹកចិត្តពួកអ្នកជឿឲ្យត្រឡប់បានដូចជាព្រះគ្រិស្ត

- បង្រៀនអ្នកជឿថ្មីឲ្យស្តាប់បង្គាប់ព្រះគ្រិស្ត

បញ្ហាគន្លឹះ:
- តើអភិវឌ្ឍ និងបង្កើតសិស្សមនុស្សមួយក្រុមដោយរបៀបណា?
- តើធ្វើគំរូអំពីការដឹកនាំដែលមានប្រសិទ្ធភាពយ៉ាងដូចម្តេច?

ដំណាក់កាលទី **IV:** ជួបជុំគ្នា (ហេព្រើរ ១០:២៤-២៥)
សកម្មភាព:
- ពង្រីកការប្រឹងប្រែងផ្សាយដំណឹងល្អ តាមរយៈបណ្តាញមិត្តភក្តិ
- ពហុគុណក្រុមកោសិកា ដោយឲ្យក្រុមកោសិកានីមួយៗ ធ្វើការឆ្ពោះទៅរកការចាប់ផ្តើមឲ្យមានក្រុមដទៃទៀត
- ចាប់ផ្តើមការថ្វាយបង្គំជាទៀងទាត់ និងជានិរន្តរ

បញ្ហាគន្លឹះ:
- តើអ្នកដឹកនាំក្រុមកោសិកាថ្មីៗ ទទួលបានការហ្វឹកហ្វឺន ហើយបញ្ជូនចេញដោយរបៀបណា?
- តើយើងធ្វើពិធីជ្រមុជទឹកឲ្យអ្នកជឿថ្មីនៅពេលណា? តើពិធីលៀងព្រះអម្ចាស់ធ្វើនៅពេលណា ហើយនរណាដឹកនាំគេធ្វើ?
- តើយើងនឹងបង្កើតឲ្យមានការប្រកបជិតស្និទ្ធនឹងគ្នា រវាងអ្នកជឿយ៉ាងដូចម្តេច? តើអ្នកជឿថ្មីនឹងត្រូវបាននាំចូលមកក្នុងការប្រកបនេះដោយរបៀបណា?
- តើយើងជួបជុំគ្នានៅពេលណា កន្លែងណា? តើយើងអញ្ជើញមនុស្សយ៉ាងដូចម្តេច?
- តើយើងនឹងប្រើទម្រង់អ្វីខ្លះ ដើម្បីសម្រេចគោលបំណងដែលយើងចង់បាន?
- តើយើងនឹងប្រើរបៀបថ្វាយបង្គំបែបណា?

ដំណាក់កាលទី **V:** អភិវឌ្ឍអ្នកដឹកនាំ (២ ធីម៉ូថេ ២:២)
សកម្មភាព:
- សង់ប្រវត្តិអ្នកដឹកនាំ (profile of leaders)ដែលត្រូវការនៅក្នុងផ្នែកនីមួយៗរបស់ព័ន្ធកិច្ច
- រកឲ្យឃើញ និងកត់ត្រាអំណោយទានខាងវិញ្ញាណរបស់សមាជិកទាំងអស់
- ហ្វឹកហ្វឺនអ្នកដឹកនាំក្រុមកោសិកា
- បែងចែក និងបញ្ជូនអ្នកដឹកនាំឲ្យទៅធ្វើព័ន្ធកិច្ច
- រៀបចំរចនាសម្ព័ន្ធ និងតួនាទីព័ន្ធកិច្ចដែលលោកអ្នកនិមិត្តឃើញសម្រាប់ព័ន្ធកិច្ច
- ថែបំប៉នអ្នកដឹកនាំ ដើម្បីផ្តល់ការគាំទ្រ

បញ្ហាគន្លឹះ:
- តើយើងជួយឲ្យអ្នកជឿថ្មីរកឃើញអំណោយទានខាងវិញ្ញាណរបស់ពួកគេបានយ៉ាងដូចម្តេច? តើនរណានឹងហ្វឹកហ្វឺនពួកគេ?
- តើត្រូវការការហ្វឹកហ្វឺនផ្នែកណាខ្លះ? តើការហ្វឹកហ្វឺនត្រូវធ្វើនៅកន្លែងណា ហើយដោយរបៀបណា?
- តើនរណាមានសក្តានុពលធ្វើជាអ្នកដឹកនាំសំខាន់? តើពួកគេមានអំណោយទាន និងសមត្ថភាពអ្វីខ្លះ? តើពួកគេជាមនុស្សដែលស្មោះត្រង់ និងចូលចិត្តបម្រើឬទេ?
- តើអ្នកដែលបានទទួលការហ្វឹកហ្វឺនទាំងនោះនឹងមានព័ន្ធកិច្ចនៅកន្លែងណា? តើអ្វីជាសេចក្តីត្រូវការ និងបញ្ហាជាមូលដ្ឋាននៅក្នុងតំបន់នោះ? តើព័ន្ធកិច្ចរបស់ពួកគេនៅក្នុងតំបន់នោះ នឹងចាប់ផ្តើមនៅពេលណា? តើពួកគេនឹងរាយការណ៍ប្រាប់អ្នកណា? តើការទទួលខុសត្រូវរបស់ពួកគេមានអ្វីខ្លះ?

ដំណាក់កាលទី **VI:** ពហុគុណ (កិច្ចការ ១:៨)
សកម្មភាព:
- បង្វឹកអ្នកដឹកនាំឲ្យបង្កើតក្រុមការងារដាំក្រុមជំនុំ
- ហ្វឹកហ្វឺនក្រុមការងារសម្រាប់ព័ន្ធកិច្ចផ្សេងៗ ដែលពាក់ព័ន្ធក្នុងការដាំក្រុមជំនុំ
- ស្រាវជ្រាវអំពីតំបន់ថ្មីដែលមនុស្សមានអារម្មណ៍ថាត្រូវចាប់ផ្ដើមព័ន្ធកិច្ច
- រៀបចំផែនការ និងបង្កើតកិច្ចប្រឹងប្រែងផ្សាយដំណឹងល្អនៅក្នុងតំបន់ថ្មី
- បង្កើតឲ្យមាន និងតែងតាំងអ្នកដឹកនាំសម្រាប់ព័ន្ធកិច្ច ដែលនឹងធ្វើការជាមួយយើង

បញ្ហាគន្លឹះ:
- តើត្រូវធ្វើការស្រាវជ្រាវអ្វីខ្លះ? តើនរណាអ្នកធ្វើ? តើមានក្រុមមនុស្សនៅជិតដែលមិនទាន់ត្រូវបានឈោងចាប់ដោយដំណឹងល្អដែរឬទេ? តើមានអ្នកដែលមានសក្ដានុពលក្លាយជាអ្នកដឹកនាំក្នុងចំណោមអ្នកដែលអាចហ្វឹកហ្វឺនបានដែរឬទេ?
- តើត្រូវកំណត់គោលដៅអ្វីខ្លះ ហើយនរណាខ្លះត្រូវដឹង? តើនរណានឹងដឹកនាំការអធិស្ឋានដើម្បីគាំទ្រព័ន្ធកិច្ចនេះ?
- តើនរណាចាត់តាំង ហើយមើលខុសត្រូវលើព័ន្ធកិច្ចដាំក្រុមជំនុំថ្មីទាំងអស់នោះ?
- តើយើងត្រូវការព័ន្ធកិច្ចហ្វឹកហ្វឺនបន្ថែម ដើម្បីហ្វឹកហ្វឺនអ្នកដឹកនាំកម្រិតផ្សេងៗសម្រាប់ចលនានេះដែរឬទេ? តើនរណាជាអ្នកហ្វឹកហ្វឺន? តើការហ្វឹកហ្វឺននោះនឹងមានលុយប្រើយ៉ាង ដូចម្ដេច?

ដំណាក់កាលទី **VII:** ចលនា (អេសាយ ១១:៩)
សកម្មភាព:
- គ្របដណ្ដប់ក្រុមមនុស្សទាំងអស់នៅក្នុងប្រទេស
- បង្កើតឲ្យមានគោលការណ៍ណែនាំដើម្បីឲ្យចលនានេះរីកចម្រើនឡើង
- កំណត់គម្រោងបេសកកម្មអន្តរវប្បធម៌ ដែលក្រុមនានានឹងឧបត្ថម្ភ
- ធ្វើការជួបជុំអធិស្ឋាន និងសរសើរតម្កើង
- កំណត់គោលដៅថ្នាក់តំបន់ និង/ឬ ថ្នាក់ជាតិ
- បង្កើតឲ្យមានកម្រិតហ្វឹកហ្វឺនដែលកាន់តែខ្ពស់សម្រាប់អ្នកដឹកនាំសំខាន់ៗនៃចលនានេះ

បញ្ហាគន្លឹះ:
- តើចលនានេះមានលក្ខណៈស្វ័យអភិវឌ្ឍ ស្វ័យទ្រទ្រង់ និងស្វ័យគ្រប់គ្រងឬទេ? ប្រសិនបើមិនដូច្នោះទេ តើត្រូវធ្វើដូចម្ដេច ដើម្បីឲ្យប្រាកដថាចលនានេះអាចធ្វើទៅកើត?
- តើតំបន់ ឬក្រុមមនុស្សណាដែលមិនទាន់ត្រូវបានឈោងចាប់នៅឡើយ? តើព្រះអម្ចាស់កំពុងដឹកនាំយើងឲ្យផ្ដួចផ្ដើមគម្រោងបេសកកម្មអ្វីខ្លះ?
- តើត្រូវការការហ្វឹកហ្វឺនប្រភេទណាខ្លះសម្រាប់ចលនានេះ? តើការហ្វឹកហ្វឺននោះនឹងទទួលបានការឧបត្ថម្ភដូចម្ដេច?
- តើអ្នកដឹកនាំ«បែបសាវក»សម្រាប់ចលនានេះ ជានរណា? តើយើងអាចធ្វើការរួមគ្នាជាមួយពួកគាត់បានដោយរបៀបណា? តើយើងអាចលើកទឹកចិត្ត និងគាំទ្រពួកគាត់បានដូចម្ដេច? តើអ្វីដែលជាសេចក្ដីត្រូវការរបស់ពួកគាត់?

ការរាយការណ៍ប្រាប់ក្រុមធំ (៣០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរអនុញ្ញាតឲ្យក្រុមនីមួយៗមានពេល៥នាទី ដើម្បីបង្ហាញផែនការសកម្មភាពរបស់ពួកគេ ពាក់ព័ន្ធនឹងដំណាក់កាលដែលបានបែងចែកឲ្យប្រាប់ដល់ក្រុមធំ។

# ម៉ោងទី ៥
# ហេតុអ្វីក្រុមតូច? (៦០ នាទី)

គ្រឹះនៅក្នុងព្រះគម្ពីរសម្រាប់ក្រុមតូច (៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល: ចូរនិយាយថា «ការប្រើក្រុមតូចសិក្សាព្រះគម្ពីរសម្រាប់ការផ្សាយដំណឹងល្អ និងការបង្កើតសិស្ស មានសារៈសំខាន់ណាស់ចំពោះវិធីសាស្ត្រដាំក្រុមជំនុំដែលមានសុខភាពល្អ ដែលត្រូវបង្រៀននៅក្នុងកម្មវិធីសិក្សានេះ។ នៅក្នុងកម្មវិធីសិក្សាខ្លះពីការដាំក្រុមជំនុំ មានការខុសប្លែកគ្នារវាងពាក្យ «ក្រុមតូច» និង «ក្រុមកោសិកា»។ នៅក្នុងកម្មវិធីសិក្សានេះ យើងនឹងប្រើពាក្យ «ក្រុមតូច» ប៉ុន្តែចាត់ទុកថាដូចគ្នានឹង «ក្រុមកោសិកា»ដែរ។

យើងឲ្យនិយមន័យក្រុមតូច (ឬក្រុមកោសិកា)ថាជាមនុស្សមួយក្រុមតូចដែលជួបជុំគ្នាដើម្បីសិក្សាព្រះបន្ទូលរបស់ព្រះ សម្រាប់គោលបំណងផ្សាយដំណឹងល្អ បង្កើតសិស្ស និងបម្រើ ដោយរួមចំណែកនៅក្នុងការបង្កើតក្រុមជំនុំថ្មីដែលមានសុខភាពល្អ និងថ្វាយបង្គំព្រះ។

ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរសួរក្រុមធំនូវសំណួរខាងក្រោម:
  ១. តើមានក្រុមដូចជាក្រុមដែលយើងហៅថាក្រុមតូច នៅក្នុងក្រុមជំនុំសញ្ញាថ្មីដែរឬទេ?
  ២. តើការដែលធ្វើឲ្យក្រុមតូចរបស់គ្រិស្តបរិស័ទ ខុសពីក្រុមដទៃៗទៀត ជាអ្វី?

សកម្មភាពស្វែងយល់ព្រះគម្ពីរជាក្រុមតូច (១៥ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរចែកជា ៤ ក្រុម
- ចូរបែងចែកសំណួរ និងអត្ថបទគម្ពីរឲ្យក្រុមនីមួយៗ
- ចូរសុំក្រុមឲ្យអានបទគម្ពីរ ដើម្បីឆ្លើយសំណួររបស់ពួកគេ និងប្រុងប្រៀបរាយការណ៍ចម្លើយរបស់ខ្លួនដោយសង្ខេប ប្រាប់ក្រុមធំ។
- ចូរសុំឲ្យក្រុមទាំងអស់ធ្វើការនៅក្នុងបន្ទប់តែមួយ
- ចូរកត់សម្គាល់ថា ក្រុមនីមួយៗមានពេល ១០ នាទី ដើម្បីបញ្ចប់សកម្មភាពនេះ
- ១០ នាទីក្រោយ (មិនចាំបាច់ត្រឡប់ចូលជាក្រុមធំវិញទេ) ចូរឲ្យក្រុមតូចនីមួយៗ

សិក្សា - ព្រះបន្ទូល - របស់ព្រះ - ផ្សាយដំណឹងល្អ - បង្កើតសិស្ស - បម្រើ - ដែលមានសុខភាពល្អ - ថ្វាយបង្គំព្រះ

រាយការណ៍ដោយសង្ខេបអំពីរបៀបដែលគេបានឆ្លើយសំណួររបស់ខ្លួន។

ក្រុម ក: តើតួនាទីផ្សាយដំណឹងល្អខ្លះរបស់ក្រុមតូចនៅក្នុងសញ្ញាថ្មី មានអ្វីខ្លះ? (កិច្ចការ ៤:២០, ៥:៤២, ២០:២០)

ក្រុម ខ: តើតួនាទីបង្កើតសិស្សខ្លះរបស់ក្រុមតូចនៅក្នុងសញ្ញាថ្មី មានអ្វីខ្លះ? (កិច្ចការ ៦:៤ កូឡុស ៤:១៧)

ក្រុម គ: តើតួនាទីប្រកបគ្នាខ្លះរបស់ក្រុមតូចនៅក្នុងសញ្ញាថ្មី មានអ្វីខ្លះ? (កិច្ចការ ២:៤២ ហេព្រើរ ១០:២៥ កិច្ចការ ២០:៧, ១១)

ក្រុម ឃ: តើតួនាទីថ្វាយបង្គំខ្លះរបស់ក្រុមតូចនៅក្នុងសញ្ញាថ្មី មានអ្វីខ្លះ? (កិច្ចការ ១:១៤, ២:៤៧, ៦:៤ កូឡុស ៤:២)

ផលប្រយោជន៍របស់ក្រុមតូច

ការពិភាក្សាជាក្រុមតូច (២០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- បន្តនៅក្នុងក្រុមតូចដូចខាងលើដដែល ចូរបែងចែកសំណួរខាងក្រោមឲ្យក្រុមនីមួយៗ។
- ចូរឲ្យក្រុមនីមួយៗត្រៀមខ្លួនចែកចាយចម្លើយរបស់ខ្លួន ប្រាប់ក្រុមដទៃទៀត។
- ប្រសិនបើអាចធ្វើបាន ចូរឲ្យក្រុមនីមួយៗសរសេរចម្លើយរបស់ខ្លួននៅលើផ្ទាំងក្រដាសធំ ដែលអាចបិតភ្ជាប់លើជញ្ជាំងជុំវិញថ្នាក់។

ក្រុម ក: តើក្រុមតូចមានផលប្រយោជន៍អ្វីខ្លះសម្រាប់ការផ្សាយដំណឹងល្អ?
តើសកម្មភាពខ្លះរបស់ក្រុមតូច ដែលអាចជួយឲ្យពួកគេឈោងចាប់ដោយដំណឹងល្អរបស់ព្រះគ្រិស្តបាន មានអ្វីខ្លះ?

ក្រុម ខ: តើក្រុមតូចមានផលប្រយោជន៍អ្វីខ្លះសម្រាប់ការបង្កើតសិស្ស?
តើសកម្មភាពខ្លះរបស់ក្រុមតូច ដែលអាចមានលទ្ធផលក្នុងការជួយការបង្រៀន និងការណែនាំ មានអ្វីខ្លះ?

ក្រុម គ: តើក្រុមតូចមានផលប្រយោជន៍អ្វីខ្លះសម្រាប់ការប្រកបគ្នា?
តើសកម្មភាពខ្លះរបស់ក្រុមតូច ដែលអាចបង្កើតការលើកទឹកចិត្តគ្នាទៅវិញទៅមក ការចែករំលែក និងមិត្តភាពនៅក្នុងព្រះគ្រិស្ត មានអ្វីខ្លះ?

ក្រុម ឃ: តើក្រុមតូចមានផលប្រយោជន៍អ្វីខ្លះសម្រាប់ការថ្វាយបង្គំ?
តើសកម្មភាពខ្លះរបស់ក្រុមតូច ដែលអាចសរសើរតម្កើង និងថ្វាយសិរីល្អដល់ព្រះ មានអ្វីខ្លះ?

ការរាយការណ៍ប្រាប់ក្រុមធំ និងការពិភាក្សា (២០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ២០ នាទីក្រោយ (សិក្ខាកាមបន្តអង្គុយនៅក្នុងក្រុមតូច) ចូរសុំឲ្យក្រុមតូចនីមួយៗរាយការណ៍ដោយសង្ខេប អំពីរបៀបដែលគេបានឆ្លើយសំណួររបស់ខ្លួន (១០ នាទី)។
- ដើម្បីបញ្ចប់ម៉ោងសិក្សានេះ ចូរដឹកនាំក្រុមក្នុងការពិភាក្សាសំណួរខាងក្រោម:
  ១. តើក្រុមតូចមានផលប្រយោជន៍អ្វីខ្លះសម្រាប់អភិវឌ្ឍអ្នកដឹកនាំ?
  ២. ដោយផ្អែកលើអ្វីៗទាំងអស់ដែលយើងបានរៀននៅក្នុងម៉ោងនេះ តើលោកអ្នកសង្ខេបផលប្រយោជន៍របស់ក្រុមតូចសម្រាប់ការដាំក្រុមជំនុំយ៉ាងដូចម្ដេច?

*សម្រាក (១៥ នាទី)*

# ម៉ោងទី ៦
# អនុញ្ញាតឲ្យព្រះគម្ពីរបង្រៀនយើង (៦០ នាទី)

វិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមាន ភាគ ១ (៦០ នាទី)

វិសេសានុមាន និងអនុមាន (២ ធីម៉ូថេ ២:១៥) (១០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល: ដោយប្រើគ្រោងខាងក្រោម ចូរពន្យល់អំពីការខុសប្លែកគ្នារវាងវិធីសាស្ត្រសិក្សាព្រះគម្ពីរ បែបវិសេសានុមាន និងបែបអនុមាន។

១. វិធីសាស្ត្រអនុមាន
- I. រកហេតុផលបែបអនុមាន
  យើងចាប់ផ្តើមជាមួយគំនិតដែលបានដឹង និងទទួលយករួចហើយ ហើយយកការសន្និដ្ឋាន ចេញពីគំនិតនោះ («អនុមាន»)
- II. ការសិក្សាព្រះគម្ពីរបែបអនុមាន
  គ្រូជាច្រើនប្រាប់ជាទូទៅថា នៅក្នុងសញ្ញាថ្មី ដំបែ ជាច្រើនដង យោងទៅរកអំពើបាប។ នៅពេលដែលយើងអានម៉ាថាយ ១៣:៣៣ យើងសន្មត់ថា ដំបែសំដៅទៅលើអំពើបាប។ ចូរអានបទគម្ពីរនោះ។ តើដំបែសំដៅទៅលើអំពើបាបដែរឬទេនៅចំណុចនេះ?
- III. វិធីសាស្ត្រ «ធម្មតា»
  ជាញឹកញាប់ គ្រូបង្រៀនព្រះគម្ពីរដឹងនូវអ្វីដែលពួកគាត់ចង់និយាយ ហើយពួកគាត់គ្រាន់តែមកឯព្រះគម្ពីរ ដើម្បីរកខគម្ពីរដែលហាក់បីដូចជាគាំទ្រការយល់ដឹងរបស់ពួកគាត់។ ហេតុអ្វីបានជាការនេះអាចបង្កគ្រោះថ្នាក់ ដោយព្រោះតែយល់ច្រឡំអត្ថន័យពិតនៃបទគម្ពីរ?

២. វិធីសាស្ត្រវិសេសានុមាន
- I. រកហេតុផលបែបវិសេសានុមាន
  យើងពិនិត្យមើលការពិតយ៉ាងយកចិត្តទុកដាក់ ដើម្បីយល់អត្ថន័យរបស់ការពិតទាំងនោះ។
- II. ការសិក្សាព្រះគម្ពីរបែវវិសេសានុមាន
  យើងពិនិត្យមើលល្អិតល្អន់លើអត្ថបទ និងបរិបទរបស់ម៉ាថាយ ១៣:៣៣ ដើម្បីកំណត់ថាតើពាក្យ «ដំបែ» កំពុងយោងទៅរកអ្វី។
- III. វិសេសានុមាន គឺជាវិធីសាស្ត្រដែលប្រសើរជាង
  នៅពេលជួយមនុស្សឲ្យរកឃើញសេចក្តីពិតក្នុងព្រះគម្ពីរ នៅពេលដែលគេសិក្សាវិធីសាស្ត្របែប វិសេសានុមាន គឺជាជម្រើសដ៏ល្អ។

ចាប់ផ្តើម _ ការសន្និដ្ឋាន _ ពិនិត្យមើល _ អត្ថបទ _ បរិបទ

ជំហាននៃការសិក្សាព្រះគម្ពីរបែបវិសេសានុមាន (២០ នាទី)
ការណែនាំសម្រាប់អ្នកសម្របសម្រួល:
- ចូរសុំឲ្យសិក្ខាកាមទាំងអស់បំពេញគ្រោងខាងក្រោមនៅក្នុងសៀវភៅលំហាត់ នៅពេលដែលលោកអ្នកចែកចាយពាក្យដែលបាត់។

ក. ការសង្កេតមើល – តើអត្ថបទគម្ពីរ *និយាយ* អំពីអ្វី?
ខ. ការបកស្រាយ – តើអត្ថបទគម្ពីរចង់ *មានន័យ* ដូចម្តេច?
គ. ការអនុវត្តន៍ – តើខ្ញុំគួរធ្វើ *អ្វី*?

ជំនួយសម្រាប់ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន

សង់គ្រឹះមួយដែលរឹងមាំ: ការនេះចាប់ផ្តើមដោយការសង្កេតមើលយ៉ាងល្អិតល្អន់។ ចូរពិនិត្យមើលខ្លឹមសារបទគម្ពីរដោយប្រុងប្រយ័ត្ន ដើម្បីកំណត់អត្ថន័យពិតប្រាកដរបស់បទគម្ពីរ ដើម្បីឲ្យគេអាចធ្វើការអនុវត្តន៍ដ៏ត្រឹមត្រូវបាន។

ចំណាយពេលគ្រប់គ្រាន់សម្រាប់ការសិក្សា៖ កុំរហ័ស ដោយចាប់ផ្តើមអានបទគម្ពីរលឿនៗ ហើយសន្មត់ថា លោកអ្នកដឹងថាបទគម្ពីរនោះមានន័យយ៉ាងដូចម្តេចនោះឡើយ។ កុំរហ័សអនុវត្តនូវអ្វីដែលបទគម្ពីរនោះបង្រៀន ទាំងមានមន្ទិលសង្ស័យឲ្យសោះ។

ការណែនាំសម្រាប់អ្នកសម្របសម្រួល៖ នៅចំណុចនេះ ចូរសួរសិក្ខាកាមថាតើពួកគេមានសំណួរអំពីវិធីសាស្ត្រសិក្សាព្រះគម្ពីរបែបវិសេសានុមានដែរឬយ៉ាងណា។ ចូរចំណាយពេលឆ្លើយសំណួររបស់ពួកគេឲ្យបានគ្រប់គ្រាន់។

របៀបសិក្សាព្រះគម្ពីរបែបវិសេសានុមាន (២៥ នាទី)

ការណែនាំសម្រាប់អ្នកសម្របសម្រួល៖ ចូរដឹកនាំថ្នាក់សិក្សាព្រះគម្ពីរយ៉ូហាន ១:១-៥ ដោយសង្ខេបតាមបែបវិសេសានុមាន។ ចូរលើកទឹកចិត្តឲ្យមានការចូលរួមនៅក្នុងដំណើរការនេះ។ ចូរសុំសិក្ខាកាមឲ្យកត់ត្រាអំពីបទគម្ពីរនេះ នៅក្នុងគ្រោងដែលមាននៅក្នុងសៀវភៅលំហាត់របស់ពួកគេ។

ការសង្កេតមើល – ការបកស្រាយ – ការអនុវត្តន៍ – ការសង្កេតមើល - ពេលវេលា

## យ៉ូហាន ១:១-៥
## ការសិក្សាព្រះគម្ពីរបែបវិសេសានុមាន

ក- ការសង្កេតមើល: តើបទគម្ពីរនេះនិយាយអំពីអ្វី?

ខ- ការបកស្រាយ: តើបទគម្ពីរនេះមានន័យដូចម្តេច?

គ- ការអនុវត្តន៍: តើខ្ញុំ/យើងគួរធ្វើអ្វី?

### ផែនការសកម្មភាពសម្រាប់ម៉ូឌុល ២: ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនបែបវិសេសានុមាន (៥ នាទី)

ក្នុងការរៀបចំសម្រាប់មេរៀនការសិក្សាព្រះគម្ពីរបែបវិសេសានុមានក្រោយទៀត ដែលនិយាយអំពីការសង្កេតមើល ចូរជ្រើសរើសបទគម្ពីរខ្លីមួយដើម្បីសិក្សា (កុំឲ្យលើសពីមួយកថាខណ្ឌ)។ ចូរចំណាយពេលយ៉ាងហោចណាស់ ១ ម៉ោង សង្កេតមើលបទគម្ពីរនោះ ហើយសុំព្រះជាម្ចាស់ឲ្យបើកភ្នែកលោកអ្នកមើលឃើញសេចក្ដីដែលលោកអ្នកមិនបានឃើញពីមុនមក។ ចូរកត់ត្រាពីការសង្កេតឃើញរបស់លោកអ្នក។ តើលោកអ្នករៀនបានអ្វី? ចូរត្រៀមខ្លួនចែកចាយបទពិសោធន៍របស់លោកអ្នក ជាមួយសហការីនៅក្នុងម៉ោងសិក្សាក្រោយទៀត។

# ការបញ្ចប់

តើបន្ទាប់ទៀតជាអ្វី?

ការណែនាំសម្រាប់អ្នកសម្របសម្រួល:

- ចូរសួររកអ្នកស្ម័គ្រចិត្តដើម្បីចែកចាយចម្លើយសំណួរខាងក្រោម តាមពាក្យពេចន៍ផ្ទាល់ខ្លួន:
  ១. តើក្រុមជំនុំដែលមានសុខភាពល្អមានន័យដូចម្តេច? (សូមមើល ម៉ោងទី ១)
  ២. តើដំណើរការជាមូលដ្ឋានក្នុងការដាំក្រុមជំនុំដែលមានសុខភាពល្អ មានន័យដូចម្តេច? (សូមមើល ម៉ោងទី ៤)
  ៣. ហេតុអ្វីបានជាការដាំក្រុមជំនុំដែលមានសុខភាពល្អ មានសារៈសំខាន់? (ទាញចេញពីម៉ោងសិក្សាទាំងអស់)
- ចូរសុំសិក្ខាកាមឲ្យចែកចាយពីអ្វីមួយដែលពួកគេបានរៀននៅក្នុងវគ្គហ្វឹកហ្វឺននេះ ដែលបានធ្វើឲ្យពួកគេរំភើបចិត្ត ឬលើកទឹកចិត្តពួកគេសម្រាប់ការងាររបស់ពួកគេ ក្នុងនាមជាអ្នកដាំក្រុមជំនុំ។
- ចូររំឭកផែនការសកម្មភាពទាំងពីរឡើងវិញ (សូមមើលម៉ោងទី ៣ និងម៉ោងទី ៦)។ ចូរឆ្លើយសំណួរពាក់ព័ន្ធនឹងផែនការទាំងនោះ។
- ចូរច្រៀងថ្វាយបង្គំមួយបទជាមួយគ្នា ហើយបញ្ចប់ ដោយអធិស្ឋានសុំព្រះពរសម្រាប់អ្នកដាំក្រុមជំនុំទាំងនេះ។

មុនពេលលោកអ្នកមកដល់ម៉ូឌុលបន្ទាប់ យើងស្នើសុំឲ្យលោកអ្នកធ្វើការខ្លះដូចខាងក្រោម:

- ចូរទាក់ទងមនុស្សថ្មីឲ្យបាន ១០ នាក់
- ប្រាប់ដំណឹងល្អដល់មនុស្ស ៥ នាក់
- ចូរចាប់ផ្តើមក្រុមតូចថ្មីមួយ

ផែនការសកម្មភាពសម្រាប់ម៉ូឌុល # ២: បញ្ជីត្រួតពិនិត្យ

- ចូរបំពេញលំហាត់ ផែនការ «អ» (សូមមើលម៉ោងទី ៣)
- ចូរចំណាយពេលសិក្សាព្រះគម្ពីរបែបវិសេសានុមាន (សូមមើលម៉ោងទី ៦)